TRUTH CENTERED TRANSFORMATION

MODULE



# អាពាហ៍ពិពាហ៍ និងក្រុមគ្រួសារ

## មគ្គុទ្ទេសក៍សម្រាប់សិស្ស

Truth Centered Transformation is a ministry of Reconciled World. Learn more at tctprogram.org.

Reconciled World

# ១.១ តួនាទីរបស់ស្វាមី និងភរិយា

## តួនាទីរបស់ស្វាមី

សូមអាន ១ កូរិនថូស ១៣៖៤-៨ អេភេសូ ២៖១-៨ និង យ៉ូហាន ១៣៖២-១៧ និងឆ្លើយសំណួរខាងក្រោម៖

១. តើខគម្ពីរទាំងនេះពណ៌នាបែបណាអំពីសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់?

- ១ កូរិនថូស ១៣៖៤-៨
- ភីលីព ២៖១-៨
- យ៉ូហាន ១៣៖២-១៧

២. តើលោកធីមូសអាចធ្វើអ្វីបាន (ចេញពីសាច់រឿងខាងលើនេះ) ដើម្បីស្រលាញ់នាងលេអាជាប្រពន្ធទៅតាមរបៀបដែលព្រះគម្ពីរបង្រៀន?

៣. តើស្វាមីអាចបង្ហាញសេចក្ដីស្រលាញ់ទៅភរិយារបស់ខ្លួន តាមរបៀបទាំងនេះបានដោយរបៀបណា? នៅក្នុងក្រុមរបស់អ្នក ចូរស្វែងរកចំណុចអនុវត្តទាំង១០ ដែលស្វាមីអាចបង្ហាញសេចក្ដីស្រលាញ់បែបនេះទៅកាន់ភរិយារបស់ខ្លួន។

# តួនាទីរបស់ភរិយា

១. តើមានអ្វីខ្លះដែលនាងលេអាអាចធ្វើ ដើម្បីធ្វើជា «អ្នកជំនួយ» និងប្រព្រឹត្តចំពោះលោកធីមូសដោយការគោរព?

២. តើយើងអាចធ្វើជា «អ្នកជំនួយ» ហើយបង្ហាញការគោរព និងចុះចូលទៅកាន់ស្វាមីដោយរបៀបណាខ្លះ? នៅក្នុងក្រុមរបស់អ្នក សូមស្វែងរកឧទាហរណ៍ឲ្យបាន១០។

៣. តើវានឹងជះឥទ្ធិពលបែបណាដល់ទំនាក់ទំនងអាពាហ៍ពិពាហ៍ ប្រសិនបើភរិយាបានធ្វើកិច្ចការទាំងនេះ?

៤. តើនឹងមានលទ្ធផលបែបណា ប្រសិនបើភរិយាមិនបានបំពេញតួនាទីរបស់ខ្លួនដូចដែលបានចែងនៅក្នុងព្រះគម្ពីរ?

# ១.២ អត្ថបទស្ដីអំពី សេចក្ដីស្រលាញ់ និង ការគោរព

មនុស្សភាពច្រើនយល់ស្របថា អាពាហ៍ពិពាហ៍មិនតែងតែងាយស្រួលនោះទេ។ ពេលខ្លះវាពិតជាលំបាកខ្លាំងណាស់។ ប្ដី/ប្រពន្ធរបស់យើងគួរតែជាមិត្តដ៏ល្អរបស់យើង និងជាអ្នកគាំទ្រខ្លាំងបំផុតនៅក្នុងពិភពលោក។ ប៉ុន្ដែវាមិនតែងតែកើតឡើងដូច្នោះនោះទេ។ ជារឿយៗ យើងតែងតែធ្វើឲ្យគ្នាឈឺចាប់ ឬឈ្លោះគ្នា។ ហេតុអ្វីបានជាជម្លោះងាយស្រួលកើតឡើងយ៉ាងដូច្នេះ និងពីរបៀបដែលយើងអាចជៀសវាងវា?

ព្រះជាម្ចាស់បានផ្ដល់ចម្លើយមកឲ្យយើងនៅក្នុងព្រះគម្ពីររួចទៅហើយ។ អត្ថបទគម្ពីរមួយសម្រាប់អាពាហ៍ពិពាហ៍គឺអេភេសូ៥។ មានគ្រិស្ដបរិសទ័ជាច្រើនដែលស្គាល់អត្ថបទគម្ពីរទាំងនេះច្បាស់ណាស់ ប៉ុន្ដែយើងត្រូវតែមើលនៅក្នុងខចុងក្រោយម្ដងទៀត។

*ទោះជាយ៉ាងណាក៏ដោយ បងប្អូនម្នាក់ៗត្រូវស្រលាញ់ភរិយារៀងៗខ្លួន*
*ដូចស្រលាញ់ខ្លួនឯង ហើយភរិយាក៏ត្រូវគោរពស្វាមីរបស់ខ្លួនដែរ។ អេភេសូ ៥៖៣៣*

យើងត្រូវបានផ្ដល់ឲ្យនូវក្រឹត្យវិន័យទូទៅពីរគឺ៖ មួយសម្រាប់ស្វាមី ហើយមួយទៀតសម្រាប់ភរិយា។ ស្វាមីត្រូវ**ស្រលាញ់**ភរិយារបស់ខ្លួន។ ភរិយាត្រូវ**គោរព**ស្វាមីរបស់ខ្លួន។ ហេតុអ្វីបានជាអ្នកគិតថាវាខុសគ្នា? ហេតុអ្វីបានភរិយាត្រូវបានប្រាប់ឲ្យគោរព ហើយស្វាមីត្រូវបានប្រាប់ឲ្យស្រលាញ់? ព្រោះតែព្រះជាម្ចាស់ទ្រង់ស្គាល់យើង ហើយទ្រង់ជ្រាបយ៉ាងច្បាស់ពីអ្វីដែលយើងត្រូវការ។ ទ្រង់ក៏ដឹងដែលថាបុរសត្រូវការការគោរព ហើយស្ត្រីត្រូវការសេចក្ដីស្រលាញ់។ បុរសក៏នៅតែចូលចិត្តសេចក្ដីស្រលាញ់ ហើយស្ត្រីក៏ត្រូវទទួលការគោរពដែរ ប៉ុន្ដែបុរសចង់បានការគោរព ហើយស្ត្រីចង់បានសេចក្ដីស្រលាញ់ជាង។

សម្រាប់ស្ត្រី វាអាចជាអ្វីមួយដែលគួរឲ្យភ្ញាក់ផ្អើល។ ស្ត្រីភាគច្រើនស្មានថាបុរសក៏ដូចជាពួកគេដែរ គ្រាន់តែចង់ឲ្យគេស្រលាញ់។ តាមពិត មានការបង្រៀនជាច្រើនផ្ដោតតែទៅលើសេចក្ដីស្រលាញ់តែប៉ុណ្ណោះ។ ការបង្រៀនឲ្យស្ត្រីចេះគោរពស្វាមីរបស់ពួកគេ ហាក់ដូចជាបានបាត់បង់ទៅហើយ (ភ្លេច)។ ស្ត្រីជាទូទៅស្មានថាស្វាមីរបស់ខ្លួនចង់ឲ្យគេស្រលាញ់ជាងចង់ឲ្យគេគោរព។ ប៉ុន្ដែវាមិនត្រឹមត្រូវនោះទេ។

ប្រសិនបើយើងមើលនៅជុំវិញខ្លួនយើង យើងឃើញពីឧទាហរណ៍ជាច្រើនពីបុរសដែលត្រូវការការគោរព ហើយស្ត្រីត្រូវការសេចក្ដីស្រលាញ់។ បើនៅក្នុងយោធា ដែលជាកន្លែងគ្រប់គ្រងដោយបុរស ហើយការគោរព និង

កិត្តិយសគឺពិតជាសំខាន់ណាស់។ បុរសប្រាថ្នាចង់ឡើងឋានៈដើម្បីទទួលបានការគោរព។ ឥរិយាបថឆ្មើងឆ្មៃនឹងមិនត្រូវបានលើកលែងឡើយ។ ការមិនចូលចិត្តមេបញ្ហាការមិនមែនជាបញ្ហាទេ។ មេបញ្ហាការមិនចង់ឲ្យគេចូលចិត្តនោះទេ ប៉ុន្តែគេចង់បានការគោរព។

ប៉ុន្តែ ប្រសិនបើអ្នកមើលទៅទស្សនាវដ្តីរបស់ស្ត្រី អ្នកនឹងឃើញថាពួកគេផ្ដោតការត្រូវបានស្រលាញ់ លើការធ្វើឲ្យខ្លួនឯងគួរឲ្យស្រលាញ់។ ស្ត្រីធ្វើអ្វីៗគ្រប់យ៉ាងដើម្បីឲ្យគេស្រលាញ់កាន់តែច្រើន។ សេចក្តីភ័យខ្លាចដ៏ធំបំផុតរបស់ស្ត្រីគឺថាមនុស្សនឹងមិនចូលចិត្តនាង។ ក៏មិនខុសគ្នាប៉ុន្មានជាមួយបុរស សេចក្តីភ័យខ្លាចដ៏ធំបំផុតរបស់គេគឺ មិនត្រូវបានគេគោរព។

ប្រសិនបើយើងចង់ឃើញអាពាហ៍ពិពាហ៍របស់យើងរីកចម្រើន នោះយើងត្រូវតែប្រាកដថាយើងធ្វើតាមក្រឹត្យវិន័យមូលដ្ឋានទាំងនេះ។ ស្វាមីត្រូវស្រលាញ់ភរិយារបស់ខ្លួន ហើយភរិយាត្រូវគោរពស្វាមីរបស់ខ្លួនផងដែរ។

**ឧបសគ្គក្នុងការប្រាស្រ័យទាក់ទង**

ដើម្បីធ្វើដូច្នេះបាន យើងត្រូវតែយល់ពីផ្នែកដែលសំខាន់មួយទៀតគឺ ការប្រាស្រ័យទាក់ទង។ បុរស និងស្ត្រីបង្ហាញនូវបំណងរបស់ខ្លួនក្នុងការចង់បានការគោរព/សេចក្តីស្រលាញ់ខុសពីគ្នាទាំងស្រុង។ អ្វីដែលស្ត្រីនិយាយភាគច្រើនមិនមែនជាអ្វីដែលបុរសឮនោះទេ។ ហើយអ្វីដែលបុរសព្យាយាមប្រាស្រ័យទាក់ទងនោះ ក៏មិនមែនជាអ្វីដែលស្ត្រីឮដែរ។

តើអ្នកដឹងដែរឬទេថា របៀបដែលស្ត្រីប្រាស្រ័យទាក់ទងថាពួកគេមានអារម្មណ៍ថាមិនត្រូវបានស្រលាញ់ ជាញឹកញាប់ធ្វើឲ្យបុរសមានអារម្មណ៍ថាមិនត្រូវបានគោរព? ហើយរបៀបដែលបុរសឆ្លើយតបនៅពេលដែលគេមានអារម្មណ៍ថាខ្លួនមិនត្រូវបានគេគោរព ធ្វើឲ្យស្ត្រីមានអារម្មណ៍ថាខ្លួនមិនត្រូវបានស្រលាញ់។ មនុស្សមួយចំនួនហៅវដ្តនោះថាវដ្តដ៏រញ៉េរញ៉ៃ ដែលយើងចង់បានសេចក្តីស្រលាញ់ និងការគោរព ប៉ុន្តែការប្រាស្រ័យទាក់ទងរបស់យើងធ្វើឲ្យយើងទាំងពីរមានអារម្មណ៍មិនសូវទទួលបានសេចក្តីស្រលាញ់ និងមិនសូវទទួលបានការគោរព។

អ្វីដែលឆោតល្ងង់បំផុតនោះគឺ យើងនៅតែបន្តធ្វើដដែលៗ ម្ដងហើយម្ដងទៀតជាមួយនឹងឥទ្ធិពលអវិជ្ជមាន។ វាមិនមានផលអ្វីនោះទេ! យើងត្រូវតែផ្លាស់ប្ដូរដើម្បីទទួលបានលទ្ធផលផ្សេង ដែលបុរសមានអារម្មណ៍ថាទទួលបានការគោរព ហើយស្ត្រីទទួលបានសេចក្តីស្រលាញ់។

ដើម្បីជួយយើងឲ្យយល់ច្បាស់ពីការនេះកាន់តែប្រសើរ សូមមើលនូវសាច់រឿងខាងក្រោមៈ

*នៅក្នុងសប្តាហ៍នេះពិតជាពិបាកណាស់ក្នុងការធ្វើការនៅឯចម្ការ។ ថ្ងៃក៏ក្តៅខ្លាំង ហើយចំហាយក្តៅក៏ពិបាកទ្រាំខ្លាំងណាស់ដែរនៅក្នុងចំការ គឺពិបាកមែនទែន។ វ៉ាន់រំភើបណាស់ ព្រោះថាគាត់ជិតដល់ម៉ោងទៅផ្ទះដើម្បីជួបប្រពន្ធរបស់គាត់។ គាត់បានចេញមកឆ្ងាយអស់១០ថ្ងៃហើយ។ វាជាពេលដ៏យូរដែលបែកឆ្ងាយចេញពីគ្រួសារ។ នៅពេលដែលគាត់ធ្វើដំណើរតាមផ្លូវ គាត់សង្ឃឹមថានាងក៏នឹងរំភើបដូចដែលគាត់ចង់ឃើញនាងដែរ។*

*ធុយនៅផ្ទះ ហើយនាងក៏ហត់នឿយក្នុងការមើលថែរក្សាកូនៗដោយមិនមានជំនួយច្រើននោះទេ រួមទាំងម្ហូរម៉ៅផងដែរ ព្រោះថាពួកគេរពឹស។ នាងទន្ទឹងរង់ចាំប្តីរបស់នាងត្រឡប់មកផ្ទះវិញ។ នាងក៏បានទូរស័ព្ទទៅកាន់គាត់ដើម្បីរំលឹកគាត់ថា កុំភ្លេចទិញទឹកដោះគោសម្រាប់កូន។ នាងមិនអាចចេញទៅក្រៅបានដោយសារតែវាពិបាកក្នុងការនាំក្មេងតូចៗទៅខាងក្រៅ។ នាងសង្ឃឹមថាគាត់នឹងត្រឡប់មកវិញឆាប់ៗ កូនតូចក៏យំម្ហូរម៉ៅ ដោយគាត់គ្មានអ្វីដើម្បីបំបៅនាង។*

**នៅពេលដែលស្ត្រីចាប់ផ្តើមមានអារម្មណ៍ពិបាកចិត្ត ឬតូចចិត្ត នោះមានន័យថានាងមានអារម្មណ៍ថាមិនបានទទួលសេចក្តីស្រលាញ់។ ម៉្យាងវិញទៀត នៅពេលដែលបុរសខឹង ឬមិននិយាយស្តី វាដោយសារតែគាត់មានអារម្មណ៍ថាមិនបានទទួលការគោរព។**

*«បងមកដល់ផ្ទះហើយអូន» វ៉ាន់និយាយ។*
*«ទីបំផុត» ធុយនិយាយ។ «ទឹកដោះគោនៅណាបង?»*
*«អឺ បងភ្លេចហើយអូន បងមានអ្វីជាច្រើនដែលត្រូវចាំ» វ៉ាន់ឆ្លើយ។*
*«ម៉េចបានបងធ្វើចឹង?» ធុយដំឡើងសម្លេង «តើបានអ្វីឲ្យកូនបៅ?»*
*«ចុះអូនឯងអត់មានអ្វីផ្សេងទេឬអ្វី? ម៉េចមិនឲ្យវាញ៉ាំអ្វីដែលយើងញ៉ាំដែរទៅ?»*
*«អត់ទេ មិនបានទេ! បងចង់ឲ្យកូនឈឺមែន? នាងជាកូនង៉ែតតូចមួយ។ ពេលខ្លះអូនគិតថាបងខ្វល់ពីមិត្តរបស់បងជាងគ្រួសារទៅទៀត។ បងមិនដែលភ្លេចទៅញ៉ាំកាហ្វេជាមួយពួកគេទេ។»*
*«មិនអីទេ ចាំបងទៅទិញ!» វ៉ាន់ស្រែកតាមបង្អួចយ៉ាងខ្លាំង។ សុភមង្គលដែលពួកគេបានរំពឹងទុកនៅពេលជួបគ្នា ក៏ត្រូវបានសោត់បាត់ទៅ ហើយជំនួសមកវិញដោយកំហឹង និងការឈឺចាប់។*

ប្រហែលជាករណីនៅក្នុងក្រុមគ្រួសាររបស់យើងខុសគ្នា ប៉ុន្តែជម្លោះតែងតែស្រដៀងគ្នា។ យើងត្រូវតែមើលឲ្យបានជ្រៅជ្រះលើសពីអ្វីដែលបាននិយាយ ក្នុងការយល់ច្បាស់ពីអ្វីដែលកំពុងតែកើតឡើង។ អ្វីដែលយើងត្រូវតែចាំនោះគឺសារៈសំខាន់នៃ**សេចក្តីស្រលាញ់ចំពោះស្ត្រី** និង**ការគោរពចំពោះបុរស។** នៅពេលដែលស្ត្រីពិបាកចិត្ត ឬតូចចិត្តនោះគឺបានន័យថានាងមានអារម្មណ៍ថាមិនបានទទួលនូវសេចក្តីស្រលាញ់។ នៅពេលដែលបុរសខឹង ឬមិននិយាយស្តីគឺវាតែងតែដោយសារតែពួកគេមានអារម្មណ៍ថាមិនត្រូវបានគេគោរព។

សូមមើលលើករណីខាងលើម្តងទៀត ដោយចងចាំគំនិតខាងលើ៖

វ៉ាន់ភ្លេចទិញទឹកដោះគោឲ្យកូនតូច។ នេះជាបញ្ហាតូចមួយទេ ហើយវាមិនគួរបង្កឲ្យមានជម្លោះដ៏ធំនោះទេ។ វ៉ាន់អាចទៅទិញបាន។ បុរសតែងតែច្របូកច្របល់ពីមូលហេតុដែលអ្វីមួយតូច អាចធ្វើឲ្យក្លាយទៅជារឿងធំបាន។ អ្វីដែលវ៉ាន់ត្រូវយល់គឺថានៅពេលដែលគាត់ភ្លេចទិញទឹកដោះគោ វាធ្វើឲ្យធុយមានអារម្មណ៍មិនទទួលបានសេចក្តីស្រលាញ់។ នាងសុំតែអ្វីម្យ៉ាងតែប៉ុណ្ណោះ ហើយគាត់បានឃ្លាតឆ្ងាយអស់ជាច្រើនថ្ងៃ។ ហេតុអ្វីបានជាគាត់ចាំមិនបានពីមួយចំណុចនោះ? តើគាត់ភ្លេចនាងដែរតើមែនទេ? តើនាងពិតជាមិនសំខាន់ទេឬអី? ដូច្នេះហើយបានជានាងឆ្លើយតបជាមួយនឹងការរិះគន់។ «ម៉េចបានបងធ្វើចឹង?» វ៉ាន់មិនបានដឹងថានាងមានអារម្មណ៍មិនទទួលបានសេចក្តីស្រលាញ់ឡើយ។ គាត់គ្រាន់តែឃើញការមួរម៉ៅរបស់នាង ហើយមានអារម្មណ៍ថាមិនទទួលបានការគោរព។ គាត់ក៏មានអារម្មណ៍មួរម៉ៅដែរ។ កំហុសរបស់គាត់ គឺអចេតនា ព្រោះគាត់មិនចង់ភ្លេចទិញទឹកគោឡើយ។ ដោយសារតែគាត់មិនបានធានាអះអាងដល់នាងពីសេចក្តីស្រលាញ់របស់គាត់ នាងក៏វាយប្រហារម្តងទៀតថា «បងមិនខ្វល់ពីពួកយើងទេ។ បងខ្វល់ពីមិត្តរបស់បងជាង។» ឥឡូវនេះ នាងកាន់តែឈឺចាប់ថែមទៀត នាងកំពុងតែវាយប្រហារលើឥរិយាបថរបស់គាត់។ នាងចង់បង្ហាញប្រាប់គាត់ថានាងពិតជាឈឺចាប់ខ្លាំងណាស់ និងមិនទទួលបានសេចក្តីស្រលាញ់ថែមទៀត។

តែទោះជាយ៉ាងណា វ៉ាន់ឆ្លើយតបដោយកំហឹង ហើយដើរចេញទៅក្រៅ។ គាន់មានអារម្មណ៍ថាមិនទទួលបានការគោរព ដោយពាក្យរិះគន់របស់នាង។ គាត់ស្ទើរតែមិនជឿ ដែលនាងនិយាយពាក្យទាំងអស់នោះ។ ហេតុអ្វីបានជានាងចោទប្រកាន់គាត់ថា គាត់មិនខ្វល់ខ្វាយពីពួកគេ នៅពេលដែលគាត់ខិតខំធ្វើការពេញមួយសប្តាហ៍ដើម្បីផ្គត់ផ្គង់ដល់ក្រុមគ្រួសារ? គាត់ចាកចេញយ៉ាងលឿនមុនពេលដែលគាត់និយាយអ្វីដែលនឹងធ្វើឲ្យសោកព្ស្តាយនៅពេលក្រោយ ឬកាន់តែអាក្រក់ជាងនេះ វាអាចបង្កហឹង្សា។ ស្ត្រីតែងតែយល់ច្រឡំពីមូលហេតុដែលបុរសដើរចេញ ហើយមិននិយាយស្តី។ ស្ត្រីស្ទើរតែមិនជឿថា បុរសមិនសូវខ្វល់ខ្វាយ ហេតុដូច្នេះបានជាពួកគេមិនចង់ដោះស្រាយជម្លោះ។ ស្ត្រីចូលចិត្តនិយាយ នៅពេលដែលពួកគេមានបញ្ហាជាមួយមិត្តភក្តិស្រីៗរបស់ពួកគេ ពួកគេតែងតែនិយាយ ហើយអ្វីគ្រប់យ៉ាងក៏ត្រូវបានដោះស្រាយ។ ប៉ុន្តែនៅពេលដែលបុរសដើរចេញ ស្ត្រីស្មានថាប្តីរបស់ពួកគេមិនស្រលាញ់ពួកគេគ្រប់គ្រាន់នោះទេ ដោយមិនចង់ដោះស្រាយបញ្ហា។ អារម្មណ៍ដែលមិនទទួលបានការស្រលាញ់ក៏កាន់តែកើនឡើង។ អ្វីដែលស្ត្រីត្រូវយល់នោះគឺថា បុរសតែងតែដើរចេញដោយសារតែគេមានអារម្មណ៍ថាឈឺចាប់ ដោយសារតែពួកគេឈឺចាប់ ហើយខឹងខ្លាំង ពួកគេមិនដឹងថាត្រូវឆ្លើយតបដោយរបៀបណានោះទេ ឬបើមិនអញ្ចឹងទេ គឺពួកគេមិនទុកចិត្តលើខ្លួនឯងដើម្បីឆ្លើយតបឲ្យបានត្រឹមត្រូវ។ ពួកគេដើរចេញដោយសារតែពួកគេចង់ការពារអ្នក ដោយសារតែពួកគេស្រលាញ់អ្នក!

វ៉ាន់ចាកចេញទៅទាំងឆ្ងល់ថា ហេតុអ្វីបានជាធុយធ្វើឲ្យមានបញ្ហាធំដោយសារតែរឿងទឹកដោះគោប៉ុណ្ណឹងសោះ។ អ្វីដែលវ៉ាន់ និងបុរសត្រូវតែដឹងនោះគឺថា ទឹកដោះគោមិនមែនជាបញ្ហានោះទេ អ្វីដែលជាបញ្ហានោះគឺធុយចង់ធានាបាននូវសេចក្តីស្រលាញ់របស់គាត់។ នាងចង់ឲ្យគាត់សុំទោសដោយចិត្តស្មោះ ហើយសុំការលើកលែងទោស ប៉ុន្តែដោយសារតែគាត់មានអារម្មណ៍ថាគាត់ត្រូវបានវាយប្រហារ និងមិនទទួលបានការគោរព គាត់ក៏ឆ្លើយតបដោយកំហឹង។ អ្វីដែលល្ងង់ខ្លៅនោះ គឺពួកគេទន្ទឹងរង់ចាំជួបមុខគ្នា។ ជាអកុសល គម្រោងការរបស់ពួកគេសម្រាប់ល្ងាចដ៏រីករាយនោះក៏ត្រូវបានបំផ្លាញ ហើយពួកគេចំណាយពេលនាល្ងាចនោះខឹងនឹងគ្នាទៅវិញ។

បុរស និងស្ត្រីមើលឃើញអ្វីៗខុសៗពីគ្នា។ ប្រសិនបើអ្នកជាស្ត្រី នោះអ្នកមានអារម្មណ៍យល់ស្របដូចធុយដែរ។ នាងនៅផ្ទះតែឯង១០ថ្ងៃហើយ។ នាងក៏ត្រូវការជំនួយដែរ។ ប្រសិនបើអ្នកជាបុរស នោះអ្នកនឹងមានអារម្មណ៍យល់ស្របនឹងវ៉ាន់។ គាត់ហត់នឿយ គាត់បានធ្វើការពេញមួយសប្តាហ៍នៅចម្ការដើម្បីផ្គត់ផ្គង់ដល់គ្រួសាររបស់គាត់! គាត់គ្រាន់តែភ្លេចប៉ុណ្ណោះ! តើនាងមិនយល់ទេឬថា គាត់ធ្វើកិច្ចការទាំងអស់នោះដើម្បីនាង និងគ្រួសារ?

វាងាយស្រួលក្នុងការយល់ស្របជាមួយអ្នកដែលមានភេទដូចយើង ដោយសារតែយើងយល់ពីគោលគំនិតដូចគ្នា។ ស្ត្រីយល់ពីរបៀបដែលស្ត្រីគិត។ ហើយបុរសយល់ពីរបៀបដែលបុរសគិត។ **ប៉ុន្តែប្រសិនបើយើងចង់មានអាពាហ៍ពិពាហ៍ដែលមានសុភមង្គល យើងត្រូវតែយល់ឲ្យប្រសើរពីរបៀបដែលអ្នកដែលមានភេទផ្ទុយគ្នាគិត។** ស្ត្រីត្រូវតែយល់ថាការរិះគន់ គឺដូចជាការមិនគោរពទៅកាន់បុរស។ បុរសក៏ត្រូវតែដឹងដែលថា ជាទូទៅស្ត្រីត្អូញត្អែររិះគន់ ឬយំដោយសារតែពួកគេមិនអារម្មណ៍មិនទទួលបានសេចក្តីស្រលាញ់។

ដូចដែលអ្នកបានឃើញ រឿងនេះងាយស្រួលក្លាយជាវដ្តដែលរញ៉េរញ៉ៃ។ នៅពេលដែលស្ត្រីកាន់តែមានអារម្មណ៍មិនទទួលបានសេចក្តីស្រលាញ់ នោះនាងនឹងកាន់តែរិះគន់ និងត្អូញត្អែរ។ នៅពេលដែលនាងកាន់តែរិះគន់ និងត្អូញត្អែរ នោះបុរសកាន់តែមានអារម្មណ៍ថាមិនទទួលបានការគោរពកាន់តែច្រើន ហើយប្រព្រឹត្តចំពោះនាងក្នុងរបៀបដែលមិនផ្តល់សេចក្តីស្រលាញ់។

គន្លឹះសម្ងាត់ក្នុងការមានអាពាហ៍ពិពាហ៍ដែលមានសុភមង្គលគឺ បញ្ច្រាសវដ្តនោះ។ យើងត្រូវតែស្តាប់បង្គាប់ព្រះជាម្ចាស់ មិនថាវាងាយស្រួលឬក៏អត់នោះទេ។ សូមចាំពីខគម្ពីរអេភេសូ ៥៖៣៣ ដែរឬទេ? ស្វាមីត្រូវស្រលាញ់ភរិយារបស់ខ្លួន ហើយភរិយាក៏ត្រូវគោរពស្វាមីរបស់ខ្លួនដែរ។ នេះជាអ្វីដែលព្រះជាម្ចាស់បានបង្គាប់។

- ភរិយា៖ ត្រូវចាំថា នៅពេលដែលអ្នកត្អូញត្អែរ ហើយរិះគន់នោះនឹងធ្វើឲ្យបុរសមានអារម្មណ៍ថាមិនទទួលបានការគោរព។ នៅពេលដែលពួកគេចាកចេញ ឬនិយាយគំរោះគំរើយ គឺដោយសារតែពួកគេមានអារម្មណ៍ថាមិនទទួលបានការគោរព។ ចូរសួរខ្លួនឯងថា «តើអ្វីដែលខ្ញុំនឹងនិយាយ ឬធ្វើនោះ នឹងធ្វើឲ្យមានការគោរពដែរឬទេ?
- ស្វាមី៖ ត្រូវចាំថា នៅពេលដែលភរិយារបស់អ្នកត្អូញត្អែរនោះ នាងធ្វើបែបនេះដោយសារតែនាងមានអារម្មណ៍ថាមិនទទួលបានសេចក្តីស្រលាញ់។ នៅពេលដែលអ្នកដើរចេញ ឬនិយាយគំរោះគំរើយ នឹងធ្វើឲ្យនាងកាន់តែមានអារម្មណ៍ថាមិនទទួលបានសេចក្តីស្រលាញ់។ មុនពេលដែលអ្នកនិយាយ ឬធ្វើសកម្មភាព ត្រូវសួរខ្លួនឯងថា «តើអ្វីដែលខ្ញុំនឹងនិយាយ ឬធ្វើនេះនឹងបង្កើតឲ្យមានសេចក្តីស្រលាញ់ឬយ៉ាងណា?

# ២.១ ការទទួលស្គាល់ពីភាពខុសគ្នារវាងយើង

១. សម្រាប់ប្រធានបទនីមួយៗ ចូរគូសសញ្ញា «X» នៅលើបន្ទាត់ ត្រង់សកម្មភាពដែលអ្នកចូលចិត្តធ្វើ (ឬឧស្សាហ៍ធ្វើ)។

២. សម្រាប់ប្រធានបទនីមួយៗ ចូរគូសសញ្ញា «O» នៅលើបន្ទាត់ ត្រង់សកម្មភាពដែលប្ដីឬប្រពន្ធ ឬក៏សមាជិកគ្រួសារជិតស្និទ្ធរបស់អ្នកចូលចិត្តធ្វើ (ឬឧស្សាហ៍ធ្វើ)។

| | | |
|---|---|---|
| | **ជម្លោះ** | |
| ដោះស្រាយភ្លាមៗ | ________________ | រក្សាភាពស្ងៀមស្ងាត់ដើម្បីមានសន្តិភាព |
| | **លុយ** | |
| ចាយ | ________________ | សន្សំ |
| | **មនុស្ស** | |
| ចំណាយពេលជាមួយអ្នកដទៃ | ________________ | ចំណាយពេលតែឯង |
| | **ផែនការ** | |
| បង្កើតផែនការ និងបន្តធ្វើវា | ________________ | ធ្វើតាមចិត្ត ដោយឥតគ្រោងទុក |
| | **ការគោរពពេលវេលា** | |
| មកដល់មុនពេល | ________________ | ទាល់ដល់ម៉ោងទើបមកដល់ ឬមកយឺត |
| | **ការសម្រាក** | |
| ចេញទៅក្រៅ | ________________ | នៅផ្ទះ |
| | **ការគេង / ដំណេក** | |
| ចូលគេងយប់ជ្រៅ | ________________ | ក្រោកពីព្រលឹម |
| | **កីឡា** | |
| រំភើប | ________________ | គ្មានចំណាប់អារម្មណ៍ |
| | **សំលៀកបំពាក់** | |
| ផ្លូវការ | ________________ | សាមញ្ញ |

| របៀបរៀបរយ | | |
|---|---|---|
| មានរបៀបរៀបរយ | ________________________ | រញ៉េរញ៉ៃ |
| **ទូរទស្សន៍** | | |
| មើលរហូត | ________________________ | បិទវាចោល |

២. បង្ហាញគ្នាទៅវិញទៅមក ពីអ្វីដែលអ្នកបានដាក់នៅលើក្រដាសរបស់អ្នក ហើយពិភាក្សា៖

ក. តើអ្នកយល់ច្បាស់ពីចំណង់ចំណូលចិត្តរបស់ដៃគូម្ខាងទៀតដែរឬទេ?

ខ. តើអ្នក និងប្តីឬប្រពន្ធ/សមាជិកគ្រួសារជិតស្និទ្ធរបស់អ្នក តែងតែមានចម្លើយដូចគ្នាសម្រាប់ប្រធានបទនីមួយៗក្នុងនេះដែរឬទេ?

គ. តើមានចំណុចណាខ្លះ ដែលចំណង់ចំណូលចិត្តរបស់អ្នក និងចំណង់ចំណូលចិត្តរបស់ពួកគេមានភាពស្រដៀងគ្នា?

ឃ. តើមានចំណុចណាខ្លះ ដែលចំណង់ចំណូលចិត្តរបស់អ្នក និងចំណង់ចំណូលចិត្តរបស់ពួកគេមានលក្ខណៈខុសគ្នាស្រឡះ?

ច. តើអ្នកអាចប្រើប្រាស់ភាពខ្លាំងរបស់មនុស្សម្នាក់ៗ ដើម្បីកសាងអាពាហ៍ពិពាហ៍ ឬទំនាក់ទំនងរបស់អ្នកបានដោយរបៀបណាខ្លះ?

ឆ. ចូរពិភាក្សា រិះរកវិធីដោះស្រាយភាពខុសគ្នាទាំងនេះក្នុងទំនាក់ទំនង ឬនៅក្នុងក្រុមគ្រួសារ។

ប្រសិនបើអ្នកទើបតែរៀបការមិនបានយូរប៉ុន្មាន នោះវាហាក់ដូចជាអ្នកមានលក្ខណៈខុសគ្នាច្រើន។ ជំនួសដោយការព្យាយាមផ្លាស់ប្តូរមនុស្សម្នាក់ទៀតនោះ អ្នកត្រូវតែមើលលើភាពខ្លាំងរបស់គាត់ហើយជួយគាត់នៅក្នុងផ្នែកណាដែលគាត់ខ្សោយ។

៣. ចូរបង្កើតជាផែនការមួយពីរបៀបដែលអ្នកនឹងដោះស្រាយផ្នែកដែលមានលក្ខណៈខុសគ្នា។ សូមជ្រើសរើសចំណុចពីរខុសគ្នា ហើយសរសេរវានៅក្នុងផែនការរបស់អ្នកពីរបៀបដែលអ្នកនឹងដោះស្រាយវា។

**ឧទាហរណទី១៖ លុយ**

ប្រសិនបើប្ដីឬប្រពន្ធរបស់អ្នកចូលចិត្តចាយវាយ ហើយអ្នកចូលចិត្តសន្សំនោះ ចូរបង្កើតផែនការមួយពីរបៀបដែលអ្នកនឹងចាយលុយមួយចំនួន និងសន្សំលុយមួយចំនួន។ ប្រហែលជាអ្នកយល់ស្របក្នុងការសន្សំក្នុងចំនួនជាក់លាក់មួយ ខណៈពេលដែលប្ដីឬប្រពន្ធរបស់អ្នកអាចមានលុយប្រចាំអាទិត្យ/ខែដើម្បីចាយវាយលើតម្រូវការរបស់គ្រួសារដោយយោងទៅតាមអ្វីដែលអ្នកយល់ស្របជាមួយគ្នា។

**ឧទាហរណ៍ទី២៖ ការសម្រាក**

ប្រសិនបើរបៀបនៃការសម្រាករបស់អ្នកគឺនៅផ្ទះ ហើយដៃគូរបស់អ្នកចូលចិត្តទៅដើរលេងនៅខាងក្រៅ ចូរព្រមព្រៀងគ្នាលើរបៀបមួយដែលអ្នកទាំងពីរអាចមានភាពសប្បាយរីករាយ។ អ្នកអាចយល់ស្របជាមួយគ្នាថា ចេញទៅក្រៅម្ដងក្នុងមួយអាទិត្យនៅពេលល្ងាច ហើយនៅផ្ទះសម្រាកជាមួយគ្នាម្ដងក្នុងមួយអាទិត្យ។ ឬក៏អ្នកអាចយល់ស្របថា ប្ដីឬប្រពន្ធរបស់អ្នកអាចទៅដើរលេងខាងក្រៅនៅពេលល្ងាច ម្ដង ឬពីរដងក្នុងមួយអាទិត្យ ហើយអ្នកនឹងនៅផ្ទះវិញ។

# ២.២ ការដោះស្រាយភាពខុសគ្នា

ចូរអានខគម្ពីរនីមួយៗ រួចសរសេរពីគោលការណ៍សំខាន់ៗអំពីរបៀបដោះស្រាយភាពខុសគ្នា។

| ខគម្ពីរ | គោលការណ៍សំខាន់ៗ |
|---|---|
| ម៉ាឃថាយ ៧៖៣-៥ | |
| ម៉ាឃថាយ ១៨៖៥ | |
| សុភាសិត ១៥៖១ | |
| កូឡុស ៤៖៦ | |
| ភីលីព ២៖៣ | |
| អេភេសូ ៤៖២៦ | |
| សុភាសិត ១៩៖១១ | |

# ៣.១ ការកំណត់ឲ្យឃើញពីការឈឺចាប់

*ដូច្នេះកាលណាអ្នកយកតង្វាយទៅថ្វាយព្រះអម្ចាស់ ហើយនៅទីនោះ អ្នកនឹកឃើញបងប្អូនណាម្នាក់មានទំនាស់នឹងអ្នក ចូរទុកតង្វាយរបស់អ្នក នៅកន្លែងថ្វាយតង្វាយ ហើយទៅស្រុះស្រួលនឹងបងប្អូនរបស់អ្នកជាមុនសិន រួមសឹមវិលមកថ្វាយតង្វាយរបស់អ្នកវិញ។ ម៉ាថាយ ៥៖២៣-២៤*

**ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន**

សុំឲ្យព្រះជាម្ចាស់បង្ហាញអ្នក ប្រសិនបើអ្នកបានធ្វើឲ្យដៃគូរបស់យើងឈឺចាប់តាមរបៀបណាមួយ។ (ប្រសិនបើអ្នកមិនទាន់រៀបការ សូមគិតពីមិត្តជិតស្និត ឬសមាជិកគ្រួសារជំនួស)។ សូមគិតពីចំនុចខាងក្រោយ ហើយសរសេរនូវគំនិតរបស់អ្នក៖

- តើមានអ្វីខ្លះដែលអ្នកគួរតែធ្វើ ប៉ុន្តែបែរជាមិនបានធ្វើ?

- តើមានអ្វីខ្លះដែលអ្នកមិនគួរធ្វើ ប៉ុន្តែបែរជាបានធ្វើ (ឬកំពុងធ្វើ)?

- តើអ្នកមិនបានបំពេញតម្រូវការរបស់ស្វាមី/ភរិយារបស់អ្នកក្នុងរបៀបណាមួយដែរឬទេ?

- តើអ្នកធ្លាប់និយាយអ្វីដែលនាំឲ្យមានការឈឺចាប់ដែរឬទេ?

- តើអ្នកធ្លាប់ខកខានក្នុងការបង្ហាញសេចក្ដីស្រលាញ់ និងការលើកទឹកចិត្តដែរឬទេ?

*ប្រសិនបើមានបងប្អូនណាម្នាក់បានប្រព្រឹត្តអំពើបាបអ្វីមួយ ចូរទៅជួបអ្នកនោះស្ងាត់ៗតែពីរនាក់ ហើយស្តីប្រដៅគាត់ទៅ បើគាត់ស្តាប់អ្នក អ្នកនឹងរក្សាបងប្អូននោះមិនឲ្យបាត់ឡើយ។*

*ម៉ាថាយ ១៨៖១៥*

**ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន**

តើអ្នកធ្លាប់មានការឈឺចាប់ដែលបង្កឡើងដោយប្តី ឬប្រពន្ធរបស់អ្នកដែរឬទេ? វាអាចជាអ្វីដែលដៃគូររបស់អ្នកដឹង ឬមិនដឹងថាបានធ្វើឲ្យអ្នកឈឺចាប់តាមរយៈការណ៍នោះ។

**ការអនុវត្ត**

ចូរអធិស្ឋាន និងប្តេជ្ញាថានឹងចាប់ផ្តើមពិភាក្សាពីចំណុចទាំងនេះជាមួយនឹងប្តី ឬប្រពន្ធរបស់អ្នកនៅសប្តាហ៍នេះ។

# ៣.២ ជំហាននៃការសុំអភ័យទោស

ជំហានសម្រាប់ការសុំអភ័យទោស ដើម្បីស្តារទំនាក់ទំនងឡើងវិញនៅពេលដែលខ្ញុំធ្វើឲ្យអ្នកដទៃឈឺចាប់៖

១. **សារភាពទៅកាន់ព្រះជាម្ចាស់៖** នៅពេលដែលយើងធ្វើឲ្យដៃគូរបស់យើងឈឺចាប់ នោះយើងក៏មិនគោរពព្រះជាម្ចាស់ដែរ។ យើងត្រូវតែចូលទៅកាន់ព្រះជាម្ចាស់ ហើយសុំការលើកលែងទោសពីទ្រង់សម្រាប់កំហុសដែលយើងបានធ្វើ។

២. **សារភាពទៅកាន់មនុស្សដទៃទៀតដោយគ្មានរកលេស៖** ភាគច្រើន នៅពេលដែលយើងសារភាពយើងចង់ពន្យល់ពីមូលហេតុដែលយើងបានធ្វើ។ តែទោះជាយ៉ាងណា វាអាចនឹងធ្វើឲ្យមនុស្សដែលលើកលែងទោសឲ្យយើងមានការពិបាកក្នុងការអត់ទោសដល់យើង។

*ឧទាហរណ៍ ១៖*

*ការស្តីបន្ទោស៖* ខ្ញុំដឹងថា ខ្ញុំបានស្តីឲ្យអ្នកនៅចំពោះមុខមិត្តរបស់អ្នកកាលពីម្សិលមិញ ប៉ុន្តែខ្ញុំនឹងមិនធ្វើដូច្នោះទេ ប្រសិនបើអ្នកមិនធ្វើឲ្យយើងមកយឺតជិតមួយម៉ោងនោះ។

*ពាក្យសមរម្យ៖* ខ្ញុំបានធ្វើឲ្យអ្នកឈឺចាប់ដោយបានស្តីឲ្យអ្នកនៅចំពោះមិត្តរបស់អ្នកកាលពីម្សិលមិញ ខ្ញុំធ្វើជ្រុលបន្តិចហើយ។

*ឧទាហរណ៍ ២៖*

*ការស្តីបន្ទោស៖* ខ្ញុំដឹងថា ខ្ញុំបានម្ទូរម៉ៅ និងហាក់ដូចជាឈ្លើយទៅកាន់អ្នកកាលពីយប់មិញ ប៉ុន្តែអ្នកគួរតែចាំថាម្តាយរបស់អ្នកបានរិះគន់ខ្ញុំច្រើនណាស់ថ្មីៗនេះ ហើយខ្ញុំហត់នឿយនឹងកិច្ចការទាំងអស់នោះខ្លាំងណាស់។

*សមរម្យ៖* ខ្ញុំអត្មានិយម ហើយឆាប់ម្ទូរម៉ៅ បានជាខ្ញុំធ្វើដូចជាឈ្លើយ និងម្ទូរម៉ៅដាក់អ្នកកាលពីយប់មិញ។ ខ្ញុំសូមទោសដែលបានធ្វើឲ្យអ្នកឈឺចាប់។

ចូរប្រៀបធៀបឧទាហរណ៍ខាងលើ តើមួយណាដែលធ្វើឲ្យអ្នកចង់លើកលែងទោសជាង?

៣. **សុំអភ័យទោស៖** ត្រូវប្រាកដថាអ្នកបញ្ជាក់ពីអ្វីដែលអ្នកចង់សុំទោស និងបង្ហាញពីទុក្ខព្រួយរបស់អ្នកដោយចិត្តស្មោះ។ ចូរនិយាយដូចជា «ខ្ញុំពិតជាសុំទោសខ្លាំងណាស់សម្រាប់អ្វីដែលខ្ញុំបានធ្វើ» ឬ «ខ្ញុំពិតជាមានអារម្មណ៍មិនល្អទេ ពីរបៀបដែលខ្ញុំបានប្រព្រឹត្តចំពោះអ្នក»។

៤. **សុំការលើកលែងទោស៖** យើងត្រូវតែយល់ថា យើងត្រូវការការលើកលែងទោស។ វាអាចថាដៃគូរបស់យើងមិនទាន់ត្រៀមខ្លួនក្នុងការលើកលែងទោសឲ្យយើងភ្លាមៗនោះទេ ដូច្នេះយើងប្រហែលជាត្រូវអត់ធ្មត់សិន។ ចូរអធិស្ឋានសុំឲ្យព្រះជាម្ចាស់ជួយដល់ដៃគូរបស់អ្នកក្នុងការលើកលែងទោសឲ្យអ្នក។ អ្នកមិនត្រូវបង្ខំពួកគេឲ្យនិយាយលើកលែងទោសប្រឆាំងនឹងឆន្ទៈរបស់ពួកគេទេ។

៥. **ផ្លាស់ប្តូរឥរិយាបថរបស់អ្នក៖** វាមិនគ្រប់គ្រាន់ទេ ក្នុងការដែលសារភាព និងសុំអភ័យទោសនោះ ប្រសិនបើយើងមានផែនការក្នុងការផ្លាស់ប្តូរ និងមានចេតនាប្រព្រឹត្តកំហុសដដែលៗ។ ផ្នែកនៃការស្តារទំនាក់ទំនងគឺប្រាកដថាអ្នកមានចិត្ត និងបំណងក្នុងការផ្លាស់ប្តូរអត្តចរិតរបស់អ្នក។ អ្នកគួរតែព្យាយាមមិនប្រព្រឹត្តវាម្តងទៀត ដោយអស់ពីសមត្ថភាព។

៦. **ទទួលយកលទ្ធផល៖** គេប្រហែលជាត្រូវការពេលដើម្បីលើកលែងទោសឲ្យអ្នក។ អ្នកត្រូវតែអត់ធ្មត់ ហើយសុំព្រះជាម្ចាស់ឲ្យជួយគេលើកលែងទោសឲ្យអ្នក។ ការឈឺចាប់ខ្លះប្រហែលជាបំផ្លាញទំនុកចិត្តនៅក្នុងទំនាក់ទំនង។ អ្នកត្រូវតែយល់ថា ប្តីឬប្រពន្ធរបស់អ្នកមិនងាយទុកចិត្តអ្នកដូចកាលពីមុននោះទេ។ នេះជាលទ្ធផលនៃសកម្មភាពរបស់អ្នក។ ការសុំអភ័យទោសមិនអាចធ្វើឲ្យអ្វីគ្រប់យ៉ាងក្លាយទៅជាថ្មីបានទេ។ ពេលខ្លះអ្នកត្រូវតែរស់នៅជាមួយនឹងលទ្ធផលនៃអ្វីដែលអ្នកបានធ្វើ។ វាត្រូវការពេលវេលាដើម្បីឲ្យការឈឺចាប់ដែលអ្នកបានបង្កឡើងនោះរសាត់ចេញទៅ។

# ៤.១ ជំហាននៃការលើកលែងទោស

ប្រសិនបើការឈឺចាប់ដែលពួកគេធ្លាប់មាននោះតូច នោះប្រហែលជាងាយស្រួលក្នុងការធ្វើតាមជំហានទាំងនេះ។ ប្រសិនបើការឈឺចាប់នោះមានលក្ខណៈធ្ងន់ធ្ងរ នោះដំណើរការនេះប្រហែលជាត្រូវការពេលវេលាបន្ថែមទៀត។

១. ទទួលស្គាល់ថាអ្វីដែលបានប្រព្រឹត្តចំពោះអ្នក គឺអយុត្តិធម៌

២. ទទួលស្គាល់នូវកំហឹង និងបំណងទាំងឡាយដែលអ្នកចង់ឲ្យគាត់ឈឺចាប់វិញ

៣. សុំឲ្យព្រះជាម្ចាស់ជួយអ្នកដើម្បីលើកលែងទោស

៤. ជ្រើសរើសថាមិនសងសឹក

៥. បោះបង់ចោលបំណងចិត្តចង់បញ្ឈឺគេនោះ

៦. ថ្វាយទំនួលខុសត្រូវក្នុងការកាត់ទោសទៅកាន់ព្រះជាម្ចាស់

៧. សុំឲ្យព្រះជាម្ចាស់ដកវាល់ទាំងភាពជូរចត់ និងការអាក់អន់ចិត្តទាំងប៉ុន្មាន

៨. សុំឲ្យព្រះជាម្ចាស់ព្យាបាលការឈឺចាប់របស់អ្នក និងលទ្ធផលនៃភាពអយុត្តិធម៌នៅក្នុងជីវិតរបស់អ្នក

**អនុវត្តជំហាននៃការលើកលែងទោស**

តើមានអ្វីមួយដែលអ្នកត្រូវលើកលែងទោសឲ្យប្តី ឬប្រពន្ធរបស់អ្នកដែរឬទេ?

ប្រសិនបើអ្នកនឹកមិនឃើញពីអ្វីមួយ ជាមួយនឹងប្តីឬប្រពន្ធរបស់អ្នកទេ សូមគិតអំពីនរណាម្នាក់ដែលធ្លាប់ប្រព្រឹត្តចំពោះអ្នកដោយអយុត្តិធម៌។ ប្រសិនបើអ្នកនៅតែនឹកមិនឃើញទេនោះ ចូរគ្រាន់តែអធិស្ឋានដោយស្ងាត់ៗសម្រាប់អ្នកដែលនឹងអនុវត្តជំហានក្នុងដំណើរការនេះ។ សូមបិទភ្នែក ហើយស្តាប់ពីជំហាននីមួយៗ។

# ៦.១ ស្ត្រី និងកុមារី

អាន លោកុប្បត្តិ ១៖២៧-២៨

នៅក្នុងខនេះបង្ហាញយើងថាទាំងស្ត្រី និងបុរសត្រូវបានបង្កើតមកឲ្យមានលក្ខណៈដូចជាព្រះជាម្ចាស់។ ចូរបង្កើតបញ្ជីមួយដែលមានបុគ្គលិកលក្ខណៈរបស់ស្ត្រី ដែលបង្ហាញយើងអំពីលក្ខណៈរបស់ព្រះជាម្ចាស់។ បន្ទាប់មក ចូរអានឃ្លានីមួយៗហើយពិភាក្សាថា តើអ្នកយល់ស្របឬមិនយល់ស្របពីវា ព្រមទាំងមូលហេតុ។

| ឃ្លា | តើអ្នកយល់ស្របឬមិនយល់ស្របពីវា ព្រមទាំងមូលហេតុ? |
|---|---|
| «មនុស្សគួរតែមើលឃើញពីស្ត្រី តែមិនគួរស្តាប់នាងទេ» | |
| «ស្ត្រីគឺជាបន្ទុកនៅក្នុងគ្រួសារ» | |
| «ស្ត្រីមិនគួរមានដីផ្ទាល់ខ្លួន ឬទទួលមរតកឡើយ» | |
| «វាមិនអីទេ ក្នុងការវាយដំភរិយាដែលមិនស្តាប់បង្គាប់នោះ» | |

តើមានទស្សនៈបែបណាខ្លះដែលអ្នកឃើញ ឬធ្លាប់បានឮនៅក្នុងវប្បធម៌របស់អ្នក ដែលបង្ហាញពីការរំពឹងទុកខុសគ្នារវាងបុរស និងស្ត្រី? តើអ្នកយល់ស្របនឹងវាដែរឬទេ?

តើមានអ្វីកើតឡើងនៅពេលដែលស្ត្រីមិនបានធ្វើតាមច្បាប់របស់វប្បធម៌ និងការរំពឹងទុកទាំងនោះ?

តើសមាជិកគ្រួសាររបស់នាងនឹងឆ្លើយតបដោយរបៀបណា (ស្វាមី ឪពុកម្តាយ គ្រួសារសាច់ថ្លៃ)?

# ៦.២ វប្បធម៌ និងរបៀបរបស់ព្រះយេស៊ូ

នៅថ្ងៃនេះយើងនឹងមើលទៅរបៀបដែលស្ត្រីត្រូវបានគេមើលឃើញក្នុងជំនាន់ព្រះយេស៊ូ និងរបៀបដែលព្រះយេស៊ូប្រព្រឹត្តចំពោះស្ត្រី។ សូមអានចំនុចនេះនៅក្នុងក្រុមតូចរបស់អ្នក ហើយពិភាក្សាសំណួរនៅក្នុងទំព័រទីពីរ។

**វប្បធម៌របស់ព្រះយេស៊ូ៖**

ក្រឹត្យវិន័យ និងប្រពៃណីរបស់សាសន៍យូដា និងរ៉ូម៉ាំងផ្តល់តម្លៃបន្តិចបន្តួចប៉ុណ្ណោះចំពោះស្ត្រី។ ស្ត្រីត្រូវបានមើលឃើញជាអ្នកតូចទាប (វណ្ណៈក្រោម និងមិនសូវសំខាន់) ដូចបុរសឡើយ។

- **ស្ត្រីត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិ៖** ពួកគេមិនអាចឯករាជ្យបានទេ។ ពួកគេអាចជាកម្មសិទ្ធិរបស់គ្រួសារឪពុក ឬជាកម្មសិទ្ធិរបស់គ្រួសារស្វាមីរបស់គេ។ បុរសសាសន៍យូដាត្រូវបានហាមឃាត់សូម្បីតែនិយាយជាមួយស្ត្រីតាមផ្លូវ។ វត្តមានរបស់ពួកគេមិនត្រូវបានកត់សម្គាល់ ឬទទួលស្គាល់នៅក្នុងព្រឹត្តការណ៍សំខាន់ៗឡើយ។
- **ស្ត្រីត្រូវបានរឹតត្បិតនៅក្នុងការថ្វាយបង្គំព្រះជាម្ចាស់៖** ពួកគេត្រូវបានអនុញ្ញាតឲ្យចូលទៅក្នុង «ទីលានសម្រាប់ស្ត្រីៗ» នៅក្នុងព្រះវិហារតែប៉ុណ្ណោះ។ ពួកគេមិនអាចអានព្រះបន្ទូល ឬចូលរួមក្នុងការថ្វាយបង្គំនៅក្នុងព្រះវិហារបានឡើយ។
- **ស្ត្រីជាទូទៅមិនត្រូវបានរាប់បញ្ចូលក្នុងការអប់រំទេ៖** ដោយសារតែការអប់រំត្រូវបានផ្តល់នៅក្នុងសាលាប្រជុំរបស់សាសន៍យូដា កុមារីមិនត្រូវបានអនុញ្ញាតឲ្យចូលរួមរៀននោះទេ។
- **ស្ត្រីគ្មានសិទ្ធិស្របច្បាប់ទេ៖** ពួកគេមិនអាចកាន់កាប់ដីធ្លី ទទួលមរតក ឬសិទ្ធិលែងលះប្តីរបស់ខ្លួនបានឡើយ។ ស្ត្រីមិនត្រូវបានអនុញ្ញាតឲ្យធ្វើជាសាក្សីនៅក្នុងច្បាប់តុលាការទេ ទាល់តែមានបុរសម្នាក់អាចបញ្ជាក់ពីរឿងរបស់ពួកគេ។

ជាទូទៅ នៅក្នុងវប្បធម៌ជំនាន់ព្រះយេស៊ូ ស្ត្រីត្រូវបានមើលឃើញថា ទទួលបានការទុកចិត្តតិចតួច មិនសូវឆ្លាត និងមិនមានភាពចាស់ទុំខាងវិញ្ញាណខ្ពស់ដូចបុរសៗនោះទេ។

**របៀបរបស់ព្រះយេស៊ូ**

ឥរិយាបថរបស់ព្រះយេស៊ូចំពោះស្ត្រី គឺខុសគ្នាឆ្ងាយពីវប្បធម៌របស់ទ្រង់។ ទ្រង់ប្រព្រឹត្តចំពោះស្ត្រី និងបុរសដោយការគោរព និងភាពថ្លៃថ្នូរស្មើៗគ្នា។ ស្ត្រីនៅក្នុងជំនាន់ទ្រង់មិនដែលស្គាល់បុរសណាដូចព្រះយេស៊ូឡើយ។

- **ព្រះយេស៊ូបានប្រព្រឹត្តចំពោះស្ត្រីដោយការគោរព និងសេចក្តីថ្លៃថ្នូរដែលមិនគួរឲ្យជឿ៖** ទ្រង់បាននិយាយជាមួយស្ត្រីក្នុងទីសាធារណៈ។ ព្រះយេស៊ូបាននិយាយជាមួយស្ត្រីសាសន៍សាម៉ារីដែលជា

សាសន៍ដទៃ និង «អ្នកមានបាប» (យ៉ូហាន ៤៖៧)។ ទ្រង់មានបន្ទូលដោយព្រះគុណ សេចក្តីពិត និង ចិត្តសប្បុរសទៅកាន់ស្ត្រីដែលត្រូវគេចាប់បានក្នុងពេលប្រព្រឹត្តអំពើផិតក្បត់ (យ៉ូហាន ៨៖១-១១)។

- **ព្រះយេស៊ូបានធ្វើព័ន្ធកិច្ចទៅកាន់ស្ត្រី និងប្រព្រឹត្តចំពោះស្ត្រីម្នាក់ៗក្នុងនាមជាមនុស្ស៖** ព្រះយេស៊ូបាន ឈោងចាប់ទៅកាន់ស្ត្រីក្នុងនាមជាមនុស្សដែលសាកសមនឹងទទួលការប្រោសឲ្យជា និងការសង្គ្រោះ ដូចជាបុរសដែរ។ ទ្រង់មិនបានអើពើនឹងច្បាប់របស់លោកម៉ូសេដែលចែងថា អ្នកមិនអាចប៉ះពាល់ស្ត្រី ដែលធ្លាក់ឈាម (ម៉ាកុស ៥៖២៥-៣៤)។ ទ្រង់បានប្រោសស្ត្រីម្នាក់ដែលត្រូវវិញ្ញាណអាក្រក់ធ្វើឲ្យពិការ អស់រយៈពេល១៨ឆ្នាំឲ្យបានជាសះស្បើយ ហើយហៅនាងថាជា «ស្ត្រីពូជពង្សរបស់លោកអប្រាហាំ» (លូកា១៣៖១០-១៧)។ ព្រះអង្គក៏បានប្រោសកូនស្រីរបស់ស្ត្រីសាសន៍កាណានឲ្យបានជាដែរ (ម៉ាថាយ ១៥៖២២-២៨)។
- **ទ្រង់បានបង្រៀនទៅកាន់ស្ត្រី៖** ព្រះយេស៊ូបានលើកពីសំណួររបស់ពួកគេ ហើយពិភាក្សារកហេតុផល យ៉ាងហ្មត់ចត់។ ព្រះយេស៊ូបានប្រាប់ពីសេចក្តីពិតខាងវិញ្ញាណទៅកាន់ស្ត្រីនិងបុរស។ ព្រះយេស៊ូបាន បង្រៀននាងម៉ារី ដែលជាប្អូនស្រីរបស់នាងម៉ាថា (លូកា ១០៖៣៨-៤២)។ ស្ត្រីជាមនុស្សដំបូងដែលបាន ឃើញព្រះអង្គមានព្រះជន្មរស់ឡើងវិញ ហើយក៏បានប្រាប់ពីដំណឹងដ៏ល្អនេះទៅកាន់ពួកសាវ័ក (យ៉ូហាន ២០៖១-១៨)។ មានស្ត្រីជាច្រើនបានធ្វើដំណើរជាមួយព្រះយេស៊ូ និងគាំទ្រដល់ព័ន្ធកិច្ចរបស់ ទ្រង់ (លូកា ៨៖១-៨) ខណៈពេលដែលទ្រង់បង្រៀនសិស្ស និងហ្វូងមនុស្ស។

**ការពិភាក្សា**

១. តើស្ត្រីត្រូវបានប្រព្រឹត្តដាក់បែបណានៅក្នុងវប្បធម៌សម័យព្រះយេស៊ូ? ចូរពណ៌នា។

២. តើមានភាពខុសគ្នាបែបណាខ្លះរវាងរបៀបដែលព្រះយេស៊ូប្រព្រឹត្តចំពោះស្ត្រី និងរបៀបដែលវប្បធម៌ របស់ទ្រង់ប្រព្រឹត្តចំពោះស្ត្រី?

៣. តើអ្នកគិតថា ស្ត្រីមានអារម្មណ៍បែបណានៅពេលដែលព្រះយេស៊ូប្រព្រឹត្តចំពោះពួកគេរបៀបនេះ?

៤. តើរបៀបដែលវប្បធម៌របស់អ្នកប្រព្រឹត្តចំពោះស្ត្រី និងរបៀបដែលវប្បធម៌របស់ព្រះយេស៊ូប្រព្រឹត្តចំពោះ ស្ត្រី មានចំណុចណាខ្លះដែលស្រដៀងគ្នា?

# ៦.៣ សហគមន៍របស់យើង

ពិភាក្សាជាមួយគ្នាអំពីផ្នែកនីមួយៗ ហើយបំពេញនៅក្នុងតារាងនេះជាមួយនឹងបញ្ហាដែលអ្នកឃើញនៅក្នុងសហគមន៍របស់អ្នកពីរបៀបដែលស្ត្រី ហើយកុមារីត្រូវបានប្រព្រឹត្តចំពោះ និងគំនិត១-២ សម្រាប់ផ្នែកនីមួយៗពីអ្វីដែលអ្នកអាចធ្វើបានដើម្បីប្រព្រឹត្តចំពោះស្ត្រី និងកុមារាជាមួយនឹងសេចក្តីថ្លៃថ្នូរ ការគោរព និងគុណតម្លៃ។

| ផ្នែក | ការប្រព្រឹត្តមិនត្រឹមត្រូវ និងភាពមិនស្មើគ្នា | តើយើងអាចធ្វើអ្វីបាន (គំនិត ១-២ សម្រាប់ផ្នែកនីមួយៗ) |
|---|---|---|
|  គ្រួសារ | | |
|  ក្រុមជំនុំ | | |
|  សាលារៀន | | |
|  សហគមន៍ | | |

- សូមប្រាប់ពីចំណុចពីរយ៉ាង ដែលអ្នកអាចធ្វើបានខុសពីមុន នៅក្នុងក្រុមគ្រួសាររបស់អ្នក ដើម្បីផ្តល់កិត្តិយសដល់ភរិយា និងកូនស្រីរបស់អ្នក។

- សូមប្រាប់ពីចំណុចពីរយ៉ាង ដែលអ្នកអាចធ្វើបានខុសពីមុន នៅក្នុងសហគមន៍របស់អ្នក ដើម្បីផ្តល់កិត្តិយសដល់ស្ត្រី និងក្មេងស្រីៗនៅក្នុងសហគមន៍របស់អ្នក។

សូមចែករំលែកជាមួយគ្នានូវអ្វីដែលអ្នកប្តេជ្ញាដើម្បីធ្វើ។ ចូរអធិស្ឋានសម្រាប់គ្នាទៅវិញទៅមក ដើម្បីសុំព្រះជាម្ចាស់ឲ្យជួយអ្នកធ្វើកិច្ចការទាំងអស់នេះ។

# ៧.១ ជួយកូនៗឲ្យរីកចម្រើន

*ចូរអប់រំកូនក្មេងឲ្យមានទម្លាប់ល្អ តាំងពីតូចគេនឹងថែរក្សាទម្លាប់នេះរហូតដល់ចាស់។*
*សុភាសិត ២២៖៦*

**ការរីកចម្រើនខាងព្រលឹងវិញ្ញាណ**

*ត្រូវទុកឲ្យព្រះបន្ទូលដែលខ្ញុំប្រគល់ដល់អ្នកនៅថ្ងៃនេះដក់ជាប់នៅក្នុងចិត្តរបស់អ្នកជានិច្ច។ ចូរបង្រៀនកូនចៅរបស់អ្នកអំពីព្រះបន្ទូលនេះ គឺត្រូវនិយាយឲ្យវាស្តាប់ ពេលអ្នកនៅផ្ទះ ពេលធ្វើដំណើរ ពេលចូលដំណេក និងពេលក្រោកពីដំណេក។ ទុតិយកថា ៦៖៦-៧*

**១. ការចំណាយជាមួយព្រះជាលក្ខណៈគ្រួសារ ឬការអានព្រះគម្ពីរ**

ព្យាយាមយកពេលខ្លះជារៀងរាល់ថ្ងៃដើម្បីអានព្រះគម្ពីរ ឬប្រាប់រឿងរ៉ាវនៅក្នុងព្រះគម្ពីរទៅកាន់កូនរបស់អ្នក។ សូមជួយពួកគេឲ្យយល់ពីរឿងទាំងអស់នោះ។ នៅពេលដែលអ្នកអានចប់នូវអត្ថបទគម្ពីរ ឬសាច់រឿងមួយ ចូរសួរសំណួរទៅកាន់ពួកគេដូចជា តើយើងអាចរៀនបានអ្វីខ្លះអំពីព្រះជាម្ចាស់ចេញពីរឿងនេះ? តើយើងអាចរៀនបានអ្វីខ្លះពីរបៀបដែលយើងគួរប្រព្រឹត្ត?

**២. ការអធិស្ឋានជាមួយកូនរបស់យើង**

យើងត្រូវយកពេលខ្លះដើម្បីអធិស្ឋានជាមួយកូនរបស់យើង។ សូមរើសម៉ោងណាដែលយើងតែងតែទំនេរ។ ត្រូវប្រាកដថាអ្នកយកពេលនោះជាមួយកូនរបស់អ្នកដោយស្តាប់ពីការខ្វល់ខ្វាយរបស់ពួកគេ និងអធិស្ឋានជាមួយពួកគេ។ នៅពេលដែលពួកគេនៅតូច ពួកគេប្រហែលជាប្រាប់អ្នកពីអ្វីដែលត្រូវអធិស្ឋាន ហើយអ្នកអធិស្ឋានខ្លីមួយ។ នៅពេលដែលពួកគេធំឡើង ពួកគេអាចចាប់ផ្តើមអធិស្ឋានបានល្អ។ សូមជួយពួកគេឲ្យឃើញនៅពេលដែលព្រះជាម្ចាស់ឆ្លើយតបនូវពាក្យអធិស្ឋានរបស់ពួកគេ។

**៣. ការចំណាយពេលាជាមួយគ្នា**

សូមនិយាយអំពីព្រះជាម្ចាស់គ្រប់ពេល។ នៅពេលដែលអ្នកទៅខាងក្រៅ ហើយឃើញដើមឈើមួយ អ្នកអាចនិយាយថាព្រះជាម្ចាស់ស្រលាញ់យើងជាខ្លាំង បានជាទ្រង់ប្រទានដើមឈើឲ្យយើងដើម្បីធ្វើជាជម្រក មានអុស/ឈើ អាហារ និងធ្វើឲ្យផែនដីមានភាពស្រស់ស្អាត។ សូមនិយាយអំពីផែនដីនេះថាជាកម្មសិទ្ធិរបស់ព្រះ ហើយទ្រង់បានប្រទានតួនាទីដល់យើងដើម្បីឲ្យមើលថែរក្សាវា។ ចូរតែងតែនឹករកវិធីដើម្បីជួយកូនរបស់អ្នកឲ្យមើលឃើញព្រះជាម្ចាស់។

**ការរីកចម្រើនខាងបញ្ញាស្មារតី**

*កូនអើយ ចូរស្តាប់ឪពុកប្រៀនប្រដៅ ហើយត្រងត្រាប់ស្តាប់ម្តាយទូន្មាន។ សុភាសិត ១៖៨*

**១. បង្រៀនក្មេងតូចនៅផ្ទះ**

ព្យាយាមពន្យល់អ្វីៗទៅកាន់ពួកគេនៅពេលដែលពួកគេនៅក្មេង និងឆ្ងល់។ បង្រៀនពួកគេពីព្យញ្ជនៈ និងលេខ ពណ៌ ទ្រង់ទ្រាយ (ត្រីកោណ ការ៉េ រង្វង់ -ល-)។ ជាមួយក្មេងតូចៗ សូមអនុញ្ញាតឲ្យពួកគេមានពីរជម្រើស សម្រាប់ការសម្រេចចិត្តដែលមិនចាំបាច់។ ឧទាហរណ៍ «តើកូនចង់ពាក់អាវពណ៌ក្រហម ឬពណ៌ខៀវនៅថ្ងៃនេះ?»

**២. បញ្ជូនក្មេងៗដែលគ្រប់អាយុទៅសាលារៀន**

ពេលខ្លះយើងត្រូវតែលះបង់ដើម្បីបញ្ជូនកូនរបស់យើងទៅសាលារៀន ប៉ុន្តែវាក៏សំខាន់ខ្លាំងណាស់ក្នុងផ្នែកជាឪពុកម្តាយ។ តាមរយៈការអប់រំ យើងអាចផ្តល់ឲ្យកូនរបស់យើងនូវឱកាសនាពេលអនាគត។ យើងមិនដឹងពីគម្រោងការដែលព្រះជាម្ចាស់មានសម្រាប់កូនរបស់យើងនោះទេ ប៉ុន្តែយើងត្រូវតែប្រាកដថាពួកគេមានឱកាសក្នុងការស្វែងរកនូវជម្រើសរបស់ពួកគេ។ ព្រះជាម្ចាស់ប្រហែលជាអាចរើសយកកូនរបស់យើងដើម្បីនាំការផ្លាស់ប្តូរដ៏ធំនៅក្នុងតំបន់របស់យើង។ ភាគច្រើនពួកគេត្រូវការការអប់រំ និងការបណ្តុះបណ្តាលដើម្បីធ្វើដូច្នោះបាន។ ការលះបង់របស់អ្នកនៅពេលនេះ ប្រហែលជាអនុញ្ញាតឲ្យកូនរបស់អ្នកបន្តការសិក្សានៅសាកលវិទ្យាល័យ និងជួយគ្រួសារនាពេលអនាគត។ បន្ថែមនៅក្នុងការអភិវឌ្ឍទំនាក់ទំនងជាមួយព្រះជាម្ចាស់ ការអប់រំគឺជាគន្លឹះដ៏សំខាន់ក្នុងការជួយពួកគេឲ្យមានជីវិតដ៏ល្អប្រសើរ។ ដូច្នេះ អ្នកត្រូវប្រាកដថាអ្នកផ្តល់ឱកាសដល់កូនរបស់អ្នក។

**ការរីកចម្រើនខាងផ្នែកសង្គម**

*កុំធ្វើអ្វីដោយចង់ប្រកួតប្រជែងគ្នា ឬដោយអួតបំប៉ោងឡើយ ផ្ទុយទៅវិញ ត្រូវដាក់ខ្លួន ហើយចាត់ទុកអ្នកឯទៀតៗថាប្រសើរជាងខ្លួន។ ភីលីព ២៖៣*

**១. បង្រៀនកូនៗពីរបៀបដែលព្រះជាម្ចាស់ចង់ឲ្យពួកគេមានទំនាកទំនងជាមួយអ្នកដទៃ**

ចូរអានខគម្ពីនីមួយៗ។ តើយើងរៀនបានអ្វីខ្លះពីខគម្ពីរទាំងអស់នេះ ដែលពិតជាសំខាន់ក្នុងការបង្រៀនកូនរបស់យើង?

- ភីលីព ២៖៣

- កូឡូស ៣៖១៣, ១៥

- ម៉ាថាយ ៥៖៤៤

- ១កូរិនថូស ១៣៖៤-៥

- ម៉ាថាយ ៧៖១២

ព្រះគម្ពីរជួយយើងឲ្យយល់ពីសារៈសំខាន់ក្នុងការរស់នៅក្នុងសន្តិភាពជាមួយអ្នកដទៃ ស្រលាញ់មនុស្សគ្រប់គ្នា ចេះអត់ធ្មត់ មានចិត្តសប្បុរស លើកលែងទោស និងប្រព្រឹត្តចំពោះអ្នកដទៃដូចដែលអ្នកចង់ឲ្យគេប្រព្រឹត្តចំពោះខ្លួន។ វាចាំបាច់ណាស់ក្នុងការនិយាយអំពីការនេះ នៅពេលដែលកូនរបស់អ្នកនៅតូច ហើយនៅពេលដែលគេធំឡើង ហើយនឹងផ្លាស់ប្ដូរទំនាក់ទំនងរបស់ពួកគេ។

**២. ធ្វើជាគំរូ។ ក្មេងៗអាចរៀនផ្នែកសង្គមបានតាមរយៈការមើលអ្នកដទៃ ជាពិសេសឪពុកម្ដាយរបស់ពួកគេ។ របៀបដែលអ្នកទំនាក់ទំនងទៅកាន់អ្នកដទៃជាឧទាហរណ៍ប្រចាំថ្ងៃទៅកាន់កូនរបស់អ្នក។** សូមពិចារណាពីរបៀបដែលអ្នកធ្វើការទំនាក់ទំនងទៅកាន់អ្នកដទៃ និងរបៀបដែលព្រះជាម្ចាស់ចង់ឲ្យអ្នកទាក់ទងទៅកាន់ពួកគេទៅតាមអ្វីដែលបានចែងនៅក្នុងព្រះគម្ពីរ។

- តើអ្នកបានធ្វើជាគំរូដ៏ល្អទៅកាន់កូនៗរបស់អ្នកដោយរបៀបណាខ្លះ?

- តើមានផ្នែកណាខ្លះ ដែលអ្នកចង់ធ្វើជាគំរូប្រសើរជាងមុនទៅកាន់កូនៗរបស់អ្នក (ដោយជំនួយពីព្រះជាម្ចាស់)?

**៣. សូមជួយកូនៗរបស់អ្នកដោះស្រាយបញ្ហានៅក្នុងទំនាក់ទំនងរបស់ពួកគេ នៅពេលដែលមានបញ្ហាកើតឡើង។**
មានពេលជាច្រើនដែលក្មេងៗមិនដែលប្រាប់អ្នកពីបញ្ហាដែលពួកគេកំពុងជួបប្រទះជាមួយអ្នកដទៃទៀត ប៉ុន្តែពួកគេនឹងចាប់ផ្ដើមប្រព្រឹត្តខុសប្លែកពីធម្មតា។ អ្នកប្រហែលជាអាចកត់សម្គាល់នៅពេលដែលគេមានកំហឹង ហឹង្សា ឬស្ងៀមស្ងាត់ខុសពីធម្មតា និងនៅដាច់ឆ្ងាយពីគេ។ សញ្ញាទាំងនេះបង្ហាញថាពួកគេអាចមានបញ្ហាជាមួយអ្នកដទៃ។ ក្មេងៗត្រូវការការគាំទ្រ និងការលើកទឹកចិត្តដើម្បីនិយាយពី

បញ្ហាទាំងអស់នេះ និងរៀនដើម្បីប្រព្រឹត្តល្អទៅកាន់អ្នកដទៃ ទោះបីជាពួកគេឈឺចាប់ មានកំហឹង ឬខ្វះការយកចិត្តទុកដាក់ពីអ្នកដទៃក៏ដោយ។ សូមអនុញ្ញាតឲ្យពួកគេចែករំលែកពីអ្វីដែលបានកើតឡើង ពីអារម្មណ៍ និងរបៀបដែលពួកគេដោះស្រាយជាមួយវា។ ការសន្ទនាប្រភេទនេះគឺជាឧទាហរណ៍ទៅកាន់កូនរបស់អ្នកពីសេចក្ដីស្រលាញ់ ការទទួលយក និងទំនាក់ទំនងដ៏ល្អ។ នេះពិតជាសំខាន់ណាស់នៅក្នុងវ័យក្មេង ដើម្បីឲ្យពួកគេទុកចិត្តអ្នកឲ្យជួយពួកគេនៅក្នុងស្ថានភាពទាំងនេះ។

តើមានរបៀបណាផ្សេងទៀត ដែលអ្នកអាចជួយកូនរបស់អ្នកឲ្យរៀនគិតពីចំណុចល្អៗរបស់អ្នកដទៃ និងប្រព្រឹត្តចំពោះពួកគេជាមួយសេចក្ដីស្រលាញ់ និងចិត្តសប្បុរស?

ទំនាក់ទំនងជាមួយអ្នកដទៃគឺពិតជាសំខាន់ណាស់។ ថ្វីបើមនុស្សទូទៅតែងមានចរិតអាត្មានិយម ប៉ុន្តែវាមិនគាប់ព្រះហឫទ័យព្រះជាម្ចាស់ទេ។ យើងចង់បង្រៀនកូនៗរបស់យើងឲ្យគិតបានល្អចំពោះអ្នកដទៃ និងប្រព្រឹត្តចំពោះអ្នកដទៃបានល្អជាងពួកគេចង់ឲ្យអ្នកដទៃប្រព្រឹត្តចំពោះខ្លួនទៅទៀត។ គោលការណ៍នេះត្រូវតែបង្រៀន និងធ្វើជាគំរូដល់កូនរបស់យើង។

**ការរីកចម្រើនខាងផ្នែកផ្លូវកាយ**

- តើមានរបៀបអ្វីខ្លះដែលយើងអាចជួយកូនរបស់យើងឲ្យរីកចម្រើនខាងផ្លូវកាយបាន?

ចំណុចទាំងនេះនឹងជួយឲ្យកូនរបស់អ្នកយើងមានរាងកាយដែលមានសុខភាពល្អ។ អ្វីដែលសំខាន់ដែលយើងត្រូវធ្វើនោះ គឺអនុញ្ញាតឲ្យកូនៗរបស់យើងធំឡើង មានសុខភាពល្អ ហើយត្រូវប្រាកដថាពួកគេមានអាហារជីវជាតិជារៀងរាល់ថ្ងៃ។ ដើម្បីឲ្យខួរក្បាលរបស់ពួកគេអភិវឌ្ឍបានល្អ យើងត្រូវប្រាកដថាពួកគេមានរបបអាហារដែលត្រឹមត្រូវ។

ច្បាប់ ១+៣៖

- ១ តំណាងឲ្យបាយ ឬអាហារស្ងៀងជំនួសដែលស្រដៀងគ្នា។ យើងត្រូវតែបរិភោគបាយឬ អាហារស្ងៀងជារៀងរាល់ថ្ងៃជាមួយនឹងអាហារពីក្រុមណាមួយក្នុងចំណោមក្រុមទាំងបី។
- ៣ តំណាងឲ្យអាហារទាំងបីក្រុមដែលយើងព្យាយាមបរិភោគឲ្យបាន ជារៀងរាល់ថ្ងៃ៖
    - ក្រុមទី១ - ប្រូតេអ៊ីន (សាងសង់សារពាង្គកាយ) ដូចជាស៊ុត ទឹកដោះគោ សណ្ដែក ត្រី និងសាច់។
    - ក្រុមទី២ - បន្លែ និងផ្លែឈើ (ពោរពេញដោយវីតាមីន និងសារធាតុចិញ្ចឹម)
    - ក្រុមទី៣ - ប្រេង និងខ្លាញ់ (ត្រូវការតែចំនួនតិចបំផុត)

# ៨.១ ការជួយដល់កុមារ ឲ្យមានអត្តចរិតល្អ

**របៀបឆ្លើយតបទៅកាន់កុមារ**

ខ្ញុំមិនចូលចិត្តកូនង៉ាដែលទើបនឹងកើតទេ! នាងអាក្រក់ណាស់!

គ្រូរបស់ខ្ញុំល្ងង់ណាស់!

វាវាយខ្ញុំ! ខ្ញុំឈប់លេងជាមួយវាទៀតហើយ!

មានរបៀបខុសៗគ្នាមួយចំនួនដែលយើងតែងតែឆ្លើយតប។ ជារឿយៗយើងមិនបានព្យាយាមជួយកូនៗរបស់យើងឲ្យយល់ពីអារម្មណ៍របស់ពួកគេនោះទេ។ ផ្ទុយទៅវិញ យើងបែរជាធ្វើរឿងដូចក្រោម៖

**ការបដិសេធ៖** «វាមិនអាក្រក់ពេកដូចកូនឯងគិតទេ។» «កូនមិនគួរនិយាយបែបនេះទេ។»

**ការឆ្លើយតបដោយមានហេតុផល៖** «កូនឯងមិនអាចធ្វើវាបានទេ កុំរអ៊ូរច្រើនពេក។» «កុំល្ងង់ពេក! កូនឯងត្រូវដឹងថា កូនឯងត្រូវទៅរៀន។» «ប្រសិនបើកូនចង់បានការងារល្អ កូនត្រូវទៅរៀន។»

**ដំបូន្មាន៖** «កូនឯងត្រូវខំប្រឹងដើម្បីរក្សាមិត្តភាពរបស់កូន បើមិនដូច្នោះទេកូនឯងនឹងគ្មានមិត្តភក្តិទេ។» «កូនឯងត្រូវតែរៀនវាយវាវិញ។»

**ការថ្កោលទោស៖** «មិចបានកូនឯងនិយាយបែបនេះ!» «កូនឯងប្រហែលជាបានធ្វើអ្វីដាក់វាហើយ។»

**សំណួរ៖** «កូនឯងបានធ្វើអ្វី?» «ហេតុអ្វីបានជាកូនឯងនិយាយអាក្រក់បែបនេះ?»

**ការពារអ្នកផ្សេង (កាន់ជើងអ្នកផ្សេង)៖** «នាងជាក្មេងស្រីដ៏ល្អ។» «ម៉ាក់/ប៉ា ប្រាកដថាវាគ្មានបំណងធ្វើអញ្ចឹងទេ។»

តើមានឧទាហរណ៍ណាផ្សេង ពីរបៀបឆ្លើយតបចំពោះចំនុចដែលបានរៀបរាប់នៅខាងលើដែរឬទេ?

**ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន៖**

តើអ្នកគិតថាអ្នកនឹងឆ្លើយតបទៅកាន់កូនរបស់អ្នកបែបណា ជាមួយនឹងឧទាហរណ៍ទាំងនេះ?

តើអ្នកគិតថា តើនឹងមានការឆ្លើយតបដូចគ្នាដូចដែលយើងបានពិភាក្សានោះដែរឬទេ?

# ៨.២ ការសម្តែង: ការស្តាប់ដោយយកចិត្តទុកដាក់ទៅកាន់ក្មេងៗ

**ឪពុក៖** កំពុងតែអង្គុយអានកាសែត។

**កូនប្រុស៖** រត់ទៅក្នុងបន្ទប់ហើយស្រែកថា «ខ្ញុំឈប់លេងជាមួយវាទៀតហើយ! ខ្ញុំស្អប់វាខ្លាំងណាស់!»

**ឪពុក៖** ដាក់កាសែតចុះ ងាកទៅកាន់កូនប្រុសហើយនិយាយថា «ប៉ាដឹងថាកូនកំពុងខឹងខ្លាំង។»

**កូនប្រុស៖** និយាយ «វាមិនសមនឹងមានមិត្តភក្តិទេ!»

**ឪពុក៖** និយាយ «អ៊ឺរ?»

**កូនប្រុស៖** និយាយ «ខ្ញុំលេងបានល្អណាស់ ហើយស៊ុតបាល់ចូលបាន២គ្រាប់ទៀត។ ហើយចុងបញ្ចប់នៅពេលដែលបានពិន្ទុស្មើគ្នា ខ្ញុំក៏ស៊ុតបាល់ខុស។»

**ឪពុក៖** និយាយ «អ៊ឹម...»

**កូនប្រុស៖** និយាយ «ហើយបន្ទាប់មកមីកា បាននិយាយនៅមុខមនុស្សគ្រប់គ្នាថា វាជាកំហុសរបស់ខ្ញុំដែលយើងលេងមិនឈ្នះនោះ។ អញ្ចឹងខ្ញុំក៏ស្រែកដាក់វា ហើយខ្ញុំក៏រត់ចេញមក...»

**ឪពុក៖** និយាយ «អញ្ចឹងកូនពិតជាខ្មាសគេណាស់ហើយ។»

**កូនប្រុស៖** និយាយខ្សឹបៗថា «បាទប៉ា វាពិតជាគួរឲ្យអាម៉ាស់ខ្លាំងណាស់ ប៉ុន្តែខ្ញុំសង្ឃឹមថាខ្ញុំនឹងមិនខឹងមីកាទេ។ ព្រោះវាជាមិត្តជិតស្និទ្ធរបស់កូន។»

**ឪពុក៖** និយាយ «ប៉ាយល់។»

**កូនប្រុស៖** និយាយ «ខ្ញុំគិតថា ខ្ញុំនឹងត្រលប់ទៅវិញ ហើយមើលថាមីកានៅទីនោះទៀតទេ។ ខ្ញុំដឹងថាវាចង់ឲ្យយើងឈ្នះខ្លាំងណាស់។»

**ឪពុក៖** ញញឹម។

# ៨.៣ គោលការណ៍នៃការស្តាប់

**ការស្តាប់ដោយប្រុងប្រយ័ត្ន**

ការស្តាប់ដោយប្រុងប្រយ័ត្នចំពោះក្មេងនឹងជួយពួកគេឲ្យដោះស្រាយជាមួយអារម្មណ៍របស់ពួកគេនៅក្នុងរបៀបដ៏ល្អ ជំនួសដោយការអាកប្បកិរិយាមិនល្អ។ វាជួយឲ្យពួកគេរៀនពីរបៀបដោះស្រាយបញ្ហា និងផ្តល់ជំនាញឲ្យពួកគេ ដែលពួកគេត្រូវមានភាពចាស់ទុំដូចមនុស្សពេញវ័យ។ វាជួយពួកគេឲ្យមានអារម្មណ៍ប្រសើរឡើងពីខ្លួនឯង និងរៀនពីរបៀបដែលមានអត្តចរិតល្អ។ វាជាជំនាញមួយដ៏សំខាន់ក្នុងការយកចិត្តទុកដាក់ជាមួយកូនៗ។

នៅពេលដែលយើងព្យាយាម ហើយលើកទឹកចិត្តក្មេងឲ្យរុញអារម្មណ៍មិនល្អចេញឲ្យឆ្ងាយ ក្មេងនឹងរឹតតែពិបាកចិត្ត។ ក្មេងអាចយកឈ្នះជាមួយអារម្មណ៍ជាច្រើន និងស្វែងរកដំណោះស្រាយផ្ទាល់ខ្លួននៅពេលដែលយើងយកចិត្តទុកដាក់ស្តាប់ពួកគេ និងអនុវត្តជាមួយគោលការណ៍ទាំងនេះ។

**គោលការណ៍នៃការស្តាប់អារម្មណ៍របស់ក្មេង៖**

**ស្តាប់ដោយយកចិត្តទុកដាក់ទាំងស្រុង**

- វាងាយស្រួលសម្រាប់ក្មេងនៅពេលដែលអ្នកធ្វើអ្វីមួយដើម្បីបង្ហាញថាអ្នកកំពុងតែយកចិត្តទុកដាក់។ ឧទាហរណ៍៖ ដាក់កាសែតចុះ និងងាកទៅកាន់កូន បែរមុខទៅកាន់កូន ដើរចេញពីចង្ក្រានបាយ និងអង្គុយចុះ។
- វាពិតជាលំបាកណាស់សម្រាប់ក្មេងក្នុងការដោះស្រាយជាមួយអារម្មណ៍ដ៏ខ្លាំងដោយខ្លួនឯង។ ប្រសិនបើគ្មានអ្នកជួយពួកគេទេ នោះអារម្មណ៍ដែលគេមាននឹងកាន់តែខ្លាំងឡើងៗ ហើយតែងតែបង្ហាញចេញជាអាកប្បកិរិយាមិនល្អ។

**ស្គាល់អារម្មណ៍របស់ពួកគេ៖**

- ប្រើឃ្លា ឬពាក្យ - *«អឺរ» ឬ «អឹម» ឬ «អើ» ឬ «បាទ/ចាស» ឬ «ប៉ា/ម៉ាក់ដឹង»។*
- ប្រើភាសាកាយវិការ - ងក់ក្បាល មើលទៅចំភ្នែករបស់ក្មេង បង្ហាញទឹកមុខ។
- មិនត្រូវធ្វើឲ្យពួកគេមានអារម្មណ៍ថាខ្លួនខុស ក្នុងការដែលមានអារម្មណ៍បែបនោះ។ ជាមួយក្មេងៗ យើងត្រូវតែទទួលយកអារម្មណ៍របស់ពួកគេ និងជួយពួកគេឲ្យដោះស្រាយជាមួយអារម្មណ៍របស់ខ្លួនដោយមិនមានអាកប្បកិរិយាមិនល្អ។

**ជួយពួកគេឲ្យស្គាល់ពីអារម្មណ៍របស់ពួកគេ៖**

- ជួយពួកគេដោយប្រើពាក្យបញ្ជាក់ពីអារម្មណ៍ ដើម្បីបង្ហាញពីអ្វីដែលអ្នកឃើញពីឥរិយាបថរបស់គេ។
- ក្មេងៗភាគច្រើនមិនអាចប្រាប់អ្នកពីអារម្មណ៍របស់គេទេ។ ប្រសិនបើអ្នកធ្វើបែបនេះចំពោះពួកគេ នោះពួកគេនឹងមានអារម្មណ៍ថាអ្នកយល់ និងទទួលយកពួកគេ។ ពួកគេនឹងតែងតែមានអារម្មណ៍ងាយស្រួល និងចាប់ផ្ដើមបន្ធូរអារម្មណ៍។ សូមកុំបារម្ភនៅពេលដែលអ្នកនិយាយអារម្មណ៍របស់គេខុស។ កូនរបស់អ្នកនឹងប្រាប់អ្នកពីអ្វីដែលអ្នកយល់ខុស។

# ៩.១ ការប្រាស្រ័យទាក់ទងវិជ្ជមាន

**ខគម្ពីរគន្លឹះ:**

- កូឡូស ៣៖២១ និង អេភេសូ ៦៖៤
  ព្រះគម្ពីរប្រាប់យើងថា យើងមិនគួរធ្វើឲ្យកូនរបស់យើង ខឹងសម្បារ ជូរចត់ ឬធ្លាក់ទឹកចិត្តនោះទេ។
- សុភាសិត ១២៖១៨
  នៅក្នុងខនេះ រំលឹកយើងថា យើងត្រូវតែប្រយ័ត្នថាយើងជ្រើសពាក្យសំដីដែលនាំការព្យាបាល មិនឲ្យមានការឈឺចាប់។

**ពាក្យបញ្ឈឺចិត្ត**

ពាក្យបញ្ឈឺចិត្តជាអ្វីដែលយើងនិយាយឲ្យធ្វើឲ្យនរណាម្នាក់ឈឺចាប់។ ភាគច្រើនយើងមិនមានចេតនាដើម្បីធ្វើឲ្យនរណាម្នាក់ឈឺចាប់នោះទេ។ តាមពិត ពាក្យទាំងនេះត្រូវបាននិយាយដើម្បីលើកទឹកចិត្តក្មេងៗឲ្យផ្លាស់ប្ដូរ ប៉ុន្តែជាលទ្ធផលវាធ្វើឲ្យក្មេងឈឺចាប់។ ជំនួសដោយការផ្លាស់ប្ដូរ ក្មេងជឿថាអ្វីដែលពួកគេឮ ធ្វើឲ្យបាក់ទឹកចិត្ត ហើយឈប់ព្យាយាមធ្វើឲ្យប្រសើរឡើង។

ពាក្យដែលធ្វើឲ្យឈឺចាប់បំផុតនោះ ស្ថិតនៅក្នុងចំណាត់ថ្នាក់ខាងក្រោម៖

- **ពាក្យសម្ដីនិយាយដោយកំហឹង និងការមួរម៉ៅ**
  - ភាគច្រើនយើងមិនមែនមានន័យដូចអ្វីដែលយើងនិយាយនោះទេ (ឧ. «បើឯងមិនកើតមក គឺល្អជាង»)
- **ស្លាកសញ្ញាដែលយើងដាក់ឲ្យក្មេង**
  - នៅពេលដែលក្មេងធ្វើអ្វីមួយដែលយើងមិនចូលចិត្ត យើងតែងតែនិយាយអ្វីពីក្មេងនោះជំនួសដោយកាយវិការ (ឧ. «ឯងជាមនុស្សដែលបរាជ័យ» ឬ «ឯងជាមនុស្សល្ងង់»)។
- **ការប្រៀបធៀប**
  - វាងាយស្រួលក្នុងការប្រៀបធៀបក្មេងម្នាក់ ជាមួយនឹងបងប្អូនប្រុសស្រីរបស់គេ (ឧ. «ម៉ែសង្ឃឹមថាឯងនឹងបានដូចបងប្រុសរបស់ឯង» ឬ «វាមិនឆ្លាតដូចបងស្រីវាទេ»)
- **ការទស្សន៍ទាយ**
  - ពេលខ្លះយើងប្រាប់ពួកគេពីអ្វីដែលនឹងកើតឡើងនាពេលអនាគត (ឧ. «ឯងនឹងមិនមានការងារធ្វើទេ» ឬ «ឯងដូចពូរបស់ឯងណាស់។ ឯងនឹងកាន់តែដូចពូរបស់ឯង»)

- **និយាយអវិជ្ជមានទៅកាន់អ្នកដទៃ**
    - ពេលខ្លះយើងនិយាយអវិជ្ជមានអំពីកូនរបស់យើងទៅកាន់អ្នកដទៃ នៅពេលដែលពួកគេឮយើងនិយាយ។ (ឧ. កូនប្រុសរបស់ខ្ញុំប្រលងធ្លាក់ទៀតហើយ។ វាមិនខំប្រឹងបន្តិចសោះ» ឬ «នេះជាកូនរបស់ខ្ញុំ។ នាងឆ្នាស់ណាស់!»)។

ភាគច្រើនពាក្យបញ្ឈឺចិត្តសម្រេចបានផ្ទុយពីអ្វីដែលយើងចង់បានពីកូនរបស់យើង។ ឧទាហរណ៍ យើងចង់ឃើញកូនរបស់យើងខិតខំប្រឹងប្រែង ប៉ុន្តែការឮពាក្យសម្ដីទាំងអស់នេះនឹងធ្វើឲ្យពួកគេជឿថា ពួកគេមិនអាចធ្វើអ្វីបានល្អនោះទេ ដូច្នេះបានជាពួកគេឈប់ប្រឹងប្រែង។ ពាក្យបញ្ឈឺចិត្តអាចបញ្ឈប់ក្មេងពីការក្លាយទៅជាអ្វីដែលព្រះជាម្ចាស់បានបង្កើតពួកគេមក។

**គោលការណ៍សម្រាប់ការប្រាស្រ័យទាក់ទងបែបវិជ្ជមាន**

១. **ពន្យល់ទៅកាន់ក្មេងពីអ្វីដែលមានចង់មានន័យឲ្យបានលឿនតាមតែអាចធ្វើបាន ប្រសិនបើអ្នកនិយាយអ្វីដែលមិនពិត។** ការនេះជួយឲ្យជៀសវាងការយល់ច្រឡំរយៈពេលវែង។

២. **សុំអភ័យទោស និងប្រាស្រ័យទាក់ទងបែបវិជ្ជមានបន្ទាប់ពីបានប្រើប្រាស់ពាក្យបញ្ឈឺចិត្តដោយកំហឹង។** ការនេះនឹងធ្វើជាគំរូនៃការសុំអភ័យទោសដល់កូនរបស់អ្នក ហើយគេអាចធ្វើតាមបាន។ វាក៏ផ្ដល់ឲ្យគេនូវឱកាសដើម្បីសុំអភ័យទោសសម្រាប់អ្វីដែលបានធ្វើឲ្យអ្នកខឹងដែរ។ ក្មេងនឹងកាន់តែគោរពអ្នក ប្រសិនបើអ្នកសុំអភ័យទោស នៅពេលដែលអ្នកធ្វើខុស ហើយវានឹងចំរុញទឹកចិត្តគេដើម្បីធ្វើឲ្យអ្នកពេញចិត្ត។

៣. **ពណ៌នាពីឥរិយាបថដែលធ្វើឲ្យអ្នកខកចិត្ត ឬខឹង ជំនួសដោយការដាក់ស្លាកសញ្ញាដល់កូន។** ការដែលនិយាយថា «ធ្វើបែបនេះ ជាទង្វើឆោតល្ងង់ណាស់!» មានប្រសិទ្ធភាពជាង និងមិនសូវឈឺចាប់ដូចការនិយាយថា «ឯងល្ងង់ណាស់!»។

៤. **មិនត្រូវប្រៀបធៀបកូនរបស់អ្នកជាមួយអ្នកដទៃ។** ការប្រៀបធៀបធ្វើឲ្យក្មេងៗមានអារម្មណ៍មិនល្អពីខ្លួនគេ និងធ្វើឲ្យមានការអាក់អន់ចិត្ត។ វាធ្វើឲ្យមានការលំបាកដល់កូនរបស់អ្នកក្នុងការចុះសម្រុងជាមួយគ្នា។

៥. **និយាយតែអ្វីវិជ្ជមានអំពីកូនរបស់អ្នកនៅពេលដែលគេអាចស្ដាប់ឮពីអ្នក។**

៦. **មិនត្រូវណែនាំបុគ្គលិកលក្ខណៈអវិជ្ជមានដល់កូនរបស់អ្នកទេ។**

**ពាក្យលើកទឹកចិត្ត**

ជំនួសដោយការប្រើពាក្យបញ្ឈឺចិត្ត យើងត្រូវតែរកឱកាសក្នុងការលើកទឹកចិត្តកូនរបស់យើង។ សូមគិតពីចំណុចប្រាំយ៉ាង ដែលអ្នកនឹងនិយាយដើម្បីលើកទឹកចិត្តកូនរបស់អ្នក។ កាន់តែក្បោះក្បាយ នោះអ្នកនឹងកាន់តែល្អប្រសើរ។

ឧទាហរណ៍ «ម៉ែពេញចិត្តណាស់ ដែលកូនតែងតែមកជួយធ្វើម្ហូបម៉ែ នៅពេលដែលកូនចេញពីសាលារៀន។ វាពិតជាល្អណាស់ក្នុងការចំណាយពេលជាមួយកូន ហើយកូនក៏បានជួយបន្ធូរការងាររបស់ម៉ែដែរ» ល្អជាងការដែលត្រឹមតែនិយាយថា «កូនជាក្មេងស្រីដែលល្អ»។

# ១០.១ ការដាក់វិន័យក្មេង

ការដាក់ទណ្ឌកម្មខាងរាង្គកាយមិនមែនមានន័យសម្រាប់តែការដាក់វិន័យលើកុមារនោះទេ។ ទាំងនេះជាជម្រើសជំនួសការដាក់ទណ្ឌកម្មលើរាង្គកាយ ដែលកាន់តែធ្វើឲ្យមានប្រសិទ្ធភាព៖

**ទម្រង់នៃជម្រើសជំនួសនៃការដាក់វិន័យជាជាងការដាក់ទណ្ឌកម្ម៖**

- ផ្តល់ឲ្យក្មេងនូវ***ភារកិច្ចដែលមានប្រយោជន៍*** ជាជាងបង្ហាញអត្តចរិតដែលមិនអាចទទួលយកបាន
- បង្ហាញ**ការមិនពេញចិត្តជាខ្លាំង** (ដោយមិនវាយប្រហារលើឥរិយាបថរបស់ក្មេង)
- បង្ហាញក្មេងពីរបៀបដែលគេអាចកែប្រែបាន
- **ផ្តល់ជម្រើស** - ឥរិយាបថដែលអាចទទួលយកបាន ឬលទ្ធផល / ដាក់ព្រំដែន
- អនុវត្តនូវលទ្ធផល
- អនុញ្ញាតឲ្យក្មេង**ទទួលរងនូវលទ្ធផល**នៃឥរិយាបថរបស់ពួកគេ

មើលទៅកាន់សាច់រឿងនីមួយៗ ហើយគិតពីស្ថានភាពមួយដែលស្រដៀងនឹងកូនរបស់អ្នកនៅឯផ្ទះ។ ស្រមៃថាអ្នកអាចប្រើវិធីជំនួសការដាក់ទណ្ឌកម្មខាងផ្លូវកាយជាមួយពួកគេ៖

**រឿងទី១** - ***ផ្តល់ឲ្យភារកិច្ចដែលមានប្រយោជន៍***

**កូន** កំពុងតែគោះចាននៅលើឥដ្ឋ ហើយទាមទារចង់បានអាហារ។

**ម្តាយស្រែក៖** «ឈប់គោះចានទៀត។ កូនអាចជួយដោយយកទឹកទៅរៀបកន្លែងញុំាបាយ។»

**រឿងទី២** - ***ការមិនពេញចិត្តជាខ្លាំង និងការរំពឹងទុកច្បាស់លាស់***

**កូន** កំពុងតែដកគំរបប៊ិចចេញ ហើយបោះប៊ិចនោះចុះឡើង។

**ម្តាយនិយាយថា៖** «កូនមិនត្រូវយកប៊ិចបងស្រីរបស់កូនមកធ្វើអញ្ចឹងនោះទេ។ ប្រសិនបើកូនខ្ចីរបស់អ្វីមួយ ម៉ែរំពឹងថាកូននឹងថែរក្សាវា។ ដាក់គំរបប៊ិចវិញភ្លាម ហើយយកវាដាក់ក្នុងប្រអប់វិញ។»

**រឿងទី៣** - *បង្ហាញពីរបៀបដែលគេអាចកែប្រែបាន*

**កូន** នៅក្នុងហាងហើយបានធ្វើបែករបស់ដោយអចេតនា។
**ម្តាយនិយាយដោយស្ងាត់ៗថា៖** «កូនរើសកម្ទេចកម្ទីនោះឡើង ហើយយើងនឹងទៅសុំទោសម្ចាស់ហាង។ ហើយម៉ែនឹងសងថ្លៃគេ។

**រឿងទី៤** - *ផ្តល់ជម្រើស ទទួលយកលទ្ធផល ហើយអនុញ្ញាតឲ្យក្មេងទទួលយកនូវលទ្ធផល*

**ម្តាយ** កំពុងរៀបចំទៅផ្សារ។
**កូនសួរ៖** «ម៉ែ ខ្ញុំសុំទៅដែរ?»
**ម្តាយនិយាយ៖** «កាលពីលើកមុន កូនមិនស្តាប់បង្គាប់ ហើយស្រែកចង់បានកូនឡានថ្មីពេលដែលដើរកាត់តូបលក់ប្រដាប់ក្មេងលេង។ កូនអាចមកបានពេលនេះ តែកូនត្រូវធ្វើរឿងមួយ។ ត្រូវស្តាប់បង្គាប់ ហើយមិនស្រែកយំនោះទេ បើមិនអញ្ចឹងទេកូនត្រូវនៅផ្ទះពេលលើកក្រោយហើយ។ កូនយល់ទេ?»
**កូនស្រែក** ចង់បានកូនឡានថ្មីនៅតូបលក់ប្រដាក់ក្មេងលេងនៅតាមផ្លូវទៅផ្សារ។ **ម្តាយ**ក៏យកគេទៅផ្ទះវិញដោយរំងាប់អារម្មណ៍។
នៅថ្ងៃបន្ទាប់ **ម្តាយ**ក៏រៀបចំខ្លួនទៅផ្សារទៀត។
**កូន**ក៏រត់មកកាន់គាត់ ហើយនិយាយថា «ម៉ែកូនសុំទៅដែរ?»
**ម្តាយនិយាយថា៖** «អត់ទេ កាលពីម្សិលមិញកូនមានជម្រើសមួយ គឺត្រូវស្តាប់បង្គាប់ បើមិនអញ្ចឹងទេកូននឹងត្រូវនៅផ្ទះ។ កូនមិនស្តាប់បង្គាប់ទេកាលពីម្សិលមិញ អញ្ចឹងកូនត្រូវនៅផ្ទះជាមួយយាយនៅថ្ងៃនេះ។ កូនអាចមកបាននៅថ្ងៃក្រោយ ប្រសិនបើកូនស្តាប់បង្គាប់។»